PTI0062

សម្ភាសន៍ជាមួយឈ្មោះ កែវ សាន ភេទប្រុស អាយុ៧៨ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ គណៈតំបន់៣៣

ស្រុកកំណើតភូមិតាំងពោធិ៍ ឃុំ៨មុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

សព្វថ្ងៃរស់នៅភូមិប្រមៅយ ឃុំប្រមៅយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០២:១១:១៣

៦៤ទំព័រ

សាន : គ្រោះថ្នាក់ទាំងអស់គ្នា បណ្ដាយមកពីអី បណ្ដាលមកពីសង្គ្រាម ។

ដានី : ចឹងលោកតា ដំបូងខ្ញុំចង់ស្គាល់ឈ្មោះលោកតា ៗឈ្មោះពេញ ឈ្មោះអី?

សាន : បាទ! ខ្ញុំឈ្មោះ កែវ សាន ។

ដានី : ឈ្មោះ កែវ សាន?

សាន : បាទ!

ដានី : លោកតាសព្វថ្ងៃអាយុប៉ុន្មានហើយ?

សាន : ៧៨ ។

ដានី : ៧៨លោកតា ។ លោកតាសព្វថ្ងៃនេះ រស់នៅភូមិឃុំអីដែរ?

សាន : ភូមិប្រមោយ ឃុំប្រមោយ ។

ដានី : ភូមិប្រមោយ ឃុំប្រមោយ?

សាន : ស្រុកវាលវែង ។

ដានី : ស្រុកវាលវែង ខេត្ត?

សាន : ពោធិ៍សាត់ ។

ដានី : លោកយាយគាត់ឈ្មោះអីដែរ?

សាន : សេក ហាន ។

ដានី : ប្រពន្ធលោកតាឈ្មោះ សេក ហាន?

សាន : បាទ!

ដានី : គាត់អាយុប៉ុន្មានដែរសព្វថ្ងៃ?

សាន ៖ អាយុ៥២ ៥៥ ។

ដានី ៖ ៥៥ ។ លោកតាមានកូនចៅទាំងអស់ប៉ុន្មាននាក់?

សាន ៖ កូនបែកអស់ហើយ នៅតែខ្ញុំ២យាយតា ។

ដានី ៖ ប៉ុន្តែកូនទាំងអស់ម៉ង ប៉ុន្មាននាក់?

សាន ៖ ៤នាក់ ។

ដានី ៖ ៤នាក់?

សាន ៖ បាទ!

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សាន ៖ ស្រី២ អឺ! ប្រុសតែ១ទេ ស្រី៣នាក់ ។

ដានី ៖ ស្រី៣ ។ លោកតាសព្វថ្ងៃប្រកបរបររកស៊ីធ្វើអីដែរ?

សាន ៖ ឥឡូវអត់ធ្វើអីកើតទេ លក់ដូរតិចតួច ។

ដានី ៖ លក់ដូរកំប៉េចកំប៉ុក?

សាន ៖ កំប៉េចកំប៉ុក គ្រាន់បានទិញម្ហូប ។

ដានី ៖ លោកតាស្រុកកំណើតលោកតានៅភូមិឃុំស្រុកអីដែរ?

សាន ៖ ភូមិតាំងពោធិ៍ ឃុំ៨មុំ ។

ដានី ៖ ភូមិ?

សាន ៖ តាំងពោធិ៍ ខាងលិចចន្លុះរពាល ។

ដានី ៖ បាទ! ភូមិតាំងពោធិ៍ ឃុំ?

សាន ៖ ៨មុំ ។

ដានី ៖ ៨មុំ ។

សាន ៖ ឥឡូវមិនដឹងគេនៅដាក់ថ្នួងដដែល នៅថ្នួង ។

ដានី ៖ ថ្នួង ខេត្តកំពង់ស្ពឺ?

សាន ៖ អឺ!

ដានី ៖ ឪពុកលោកតាគាត់ឈ្មោះអីទៅ?

សាន ៖ កែវ អឿ ។

ដានី ៖ កែវ អឿ ។ គាត់ខូចតាំងពីអង្កាល់?

សាន ៖ អឺ! វែងណាស់ តាំងពីសង្គ្រាមទី២នោះ តាំងពីឆ្នាំភាគទី៤ ច័ន្ទរង្សី...មិនដឹងឆ្នាំប៉ុន្មានទេ ខ្ញុំមិនចាំទេ ។

ដានី :	តាំងពីជំនាន់សង្គ្រាមរាស្ត្រនិយមម៉េះ?

សាន :	មុនៗ

ដានី :	មុនសង្គមរាស្ត្រនិយមទៀត?

សាន :	បាទ! គាត់ស្លាប់ដោយសារ គេចាប់យកទៅវៃគាត់ទៅ។

ដានី :	គេចោទគាត់ថាម៉េច?

សាន :	កាលនោះ គាត់នៅទាហានយួន គាត់នៅជាមួយយួនចូលស្រុកខ្មែរ ឆ្នាំ១៩៤០ ៤៤។

ដានី :	ចុះម្ដាយ?

សាន :	ម្ដាយស្លាប់ហើយ។

ដានី :	ម្ដាយលោកតាគាត់ឈ្មោះអីដែរ?

សាន :	កែវ មួង។

ដានី :	កែវ ដូចគ្នា?

សាន :	បាទ! ត្រកូលគាត់ដូចគ្នា។

ដានី :	កែវ មួង គាត់ស្លាប់តាំងពីអង្កាល់ដែរ?

សាន :	អានឹងស្លាប់៦៨។

ដានី :	ស្លាប់៦៨?

សាន :	៦៨ ៦៩។

ដានី :	ចុះលោកបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់?

សាន :	៨។

ដានី :	បងប្អូន៨នាក់។ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សាន :	ប្រុសតែ៣។

ដានី :	ប្រុស៣ ស្រី៥។ ចឹងលោកតាកូនទីប៉ុន្មាន?

សាន :	ខ្ញុំទី៤។

ដានី :	កូនទី៤។ ចឹងកាលពីក្មេងៗលោកតារៀនសូត្រអីនៅ?

សាន :	អត់ទេ អត់បេះទេ នៅវត្តតិចតួច។

ដានី :	នៅវត្ត?

សាន :	បាទ! ២ឆ្នាំ បួសម៉ាឆ្នាំ នៅវត្តម៉ាឆ្នាំ។

ដានី :	នៅវត្តម៉ាឆ្នាំ បួស២ឆ្នាំ?

សាន ៖ ឬសម៉ាដែរ នៅបាន២ឆ្នាំ វល់មើលគោមើលអី ចាស់ពីដើមមិនបានរៀនមិនបានសូត្រចេះដឹង ។

ដានី ៖ លោកតានៅវត្ត ហើយនឹងបួសនឹងនៅវត្តណាទៅ?

សាន ៖ តាំងគោក ។

ដានី ៖ វត្តតាំងគោក ។ ដល់ពេលសឹកមកវិញ លោកតាធ្វើអីទៅ?

សាន ៖ ធ្វើស្រែ ។

ដានី ៖ ឆ្នាំណាទៅដែលលោកតាសឹកពី?

សាន ៖ អត់ចាំទេ ។

ដានី ៖ តាំងពីមុនប្រហែលជាអន្ទង់ឆ្នាំប៉ុន្មាន រដ្ឋប្រហារមុនយូរ?

សាន ៖ មុនយូរ តាំងពី៤១ ៤២ ៤៣ ៤៤នឹង ។

ដានី ៖ សឹកពីបួសមកធ្វើស្រែៗជាមួយឪពុកម្តាយ ។

សាន ៖ បាទ! ជាមួយម្តាយឪពុក ។

ដានី ៖ ចុះពេលណាទៅបានលោកតារៀបការ?

សាន ៖ ភ្លេចហើយ មិនដឹងឆ្នាំប៉ុន្មានៗ ខ្ញុំអត់ចាំទេ សឹកពីបួសមក៦ឆ្នាំ បានការ ។

ដានី ៖ ចឹងជាមួយលោកយាយមុន?

សាន ៖ បាទ!

ដានី ៖ ចុះរៀបការជាមួយលោកយាយមុន គាត់ឈ្មោះអីដែរ?

សាន ៖ ឈ្មោះ ជុំ ជិន ជុំ ។

ដានី ៖ គាត់អ្នកស្រុកណាដែរ ស្រុកគាត់?

សាន ៖ ស្រុក៨មុំនឹងដែរ ។

ដានី ៖ នៅ៨មុំ តាំងពោធិ៍ដែរអត់ទេ?

សាន ៖ បាទ! តាំងពោធិ៍ ភូមិតែមួយ ។

ដានី ៖ នៅភូមិជាមួយគ្នា ។ ចុះដល់ពេលរៀបការជាមួយគាត់ហើយ លោកតានៅក្នុងភូមិតែមួយឬយ៉ាងម៉េចទៀត?

សាន ៖ នៅភូមិតែមួយ ។

ដានី ៖ នៅភូមិធ្វើអីទៅកាលនឹង?

សាន ៖ កាលនឹងធ្វើយុវ័ន្ត ។

ដានី ៖ ធ្វើយុវន្ត?

សាន ៖ យុវ័ន្តជីវពល ។ នៅយុវ័ន្តរហូត ខ្ញុំនៅយុវ័ន្តតាំងពីសឹកពីបួសមក ។

ដានី ៖ យុវ័ន្ត ចឹងយុវ័ន្តនឹងគេធ្វើអីខ្លះទៅ?

សាន ៖ ការពារភូមិឃុំៗស្រុក ម៉ាស្រុកយុវ័ន្តមានក្មេងៗមានប៉ុន្មានបំពាក់អាវុធ ចូលយុវ័ន្តទាំងអស់ ។

ដានី ៖ ការពារនឹង យើងការពារដូចថាការពារ?

សាន ៖ ចោរស្អីៗទាំងអស់ ប្រតិកម្មអីកើតឡើង សមរភូមិក្នុងស្រុកនឹង មិនបាច់ទៅហៅប៉ូលីសហៅទាហានហៅទេ ព្រោះគ្រាប់កាំភ្លើងមានទាំងអស់ ខទាហរណ៍ថាខ្ញុំទទួលខុសត្រូវមនុស្ស ១០០នាក់ៗក្តាប់អាវុធនឹង ។ ក្នុងឃុំនឹងវាមានកាំភ្លើង១៨០ដើម ។

ដានី ៖ ចឹងលោកតាធ្វើប្រធានយុវ័ន្តនៅភូមិ?

សាន ៖ ប្រធានយុវ័ន្ត ។

ដានី ៖ ប្រធានយុវ័ន្តឃុំហើយក៏?

សាន ៖ យុវ័ន្តក្នុងឃុំ តែទទួលម៉ាស្រុក ខទាហរណ៍ថាក្មួយឯងមួយនៅឃុំនោះ ខ្ញុំមួយនៅឃុំនេះ ហើយឃុំនោះ ចឹងទៅយុវ័ន្តក្មួយឯងមួយ ខ្ញុំមួយទទួលម៉ាផ្នែកទៅម៉ាឃុំទៅ ។ ដល់ទៅ៣-៤-១០-១៥ឃុំចឹង ១៥ឃុំ ។

ដានី ៖ ចឹងយុវ័ន្តនឹងមានគ្នាប៉ុន្មានទៅ?

សាន ៖ ១៨០ ។

ដានី ៖ យុវ័ននឹង១៨០មានកាំភ្លើងគ្រប់ដៃ?

សាន ៖ មានកាំភ្លើងគ្រប់ដៃ ។

ដានី ៖ ក្នុងនឹងសម័យសម្តេច?

សាន ៖ សម័យសម្តេចតា ។

ដានី ៖ សម័យសម្តេចតា?

សាន ៖ ពលរដ្ឋមានសិទ្ធិប្រើប្រាស់អាវុធ ហើយការពារភូមិឃុំខ្លួនឯង ក្រោយពីចាប់បារាំងទៅស្រុក ។

ដានី ៖ ចឹងលោកតាកាលនឹងធ្វើយុវ័ន្ត ហើយប្រពន្ធលោកតាគាត់ធ្វើអី?

សាន ៖ អត់ធ្វើអីទេ ។

ដានី ៖ មានធ្វើស្រែធ្វើអីដែរ?

សាន ៖ ធ្វើតែស្រែ ។

ដានី ៖ ធ្វើតែស្រែ?

សាន ៖ បាទ! យុវ័ន្តនៅផ្ទះគាន់គាំភ្លើងធម្មតា គាំភ្លើងនៅចោលផ្ទះទៅ យប់ឡើងមានការអីដើរធ្វើការតាមភូមិយើង ចែកគ្នាយាមអី មានចោរ មានឈ្មួញមកចូលស្រុកភូមិយើង អត់មានអីប៉ូលិសអីណា សន្តិសុខអី ប៉ូលីសមកសួរនាំតែមេយុវ័ន្តនឹងទៅ តាមភូមិដូចខ្ញុំនៅភូមិនឹងភូមិនោះមកជួបខ្ញុំៗឲ្យទៅសួរឈ្មោះមួយទៀតនៅភូមិនោះមួយទៀតទៅ ។ ហើយរាយការណ៍តាមលំដាប់ដូចយើងទាហាន ដូចយើងប៉ូលីសក្រោយចឹង ។

ដានី ៖ ហើយចឹងលោកតាធ្វើយុវ័ន្តនឹងរហូតដល់ពេលណាទៅ?

សាន ៖ ពេលរដ្ឋប្រហារ ។

ដានី ៖ ដល់ពេលរដ្ឋប្រហារឆ្នាំ៧០ ?

សាន ៖ បាទ!

ដានី ៖ កាលនឹងលោកតាមានកូនចៅទេ?

សាន ៖ មាន ទាំងអស់ ទាំង៤ ។

ដានី ៖ កូន៤នឹង?

សាន ៖ បាទ!

ដានី ៖ ចឹងជាមួយយាយក្រោយអត់មានកូនទេ?

សាន ៖ អត់ទេ ។

ដានី ៖ ចុះលោកយាយមុនគាត់?

សាន ៖ នៅ ។

ដានី ៖ គាត់នៅណាដែរ?

សាន ៖ នៅនឹងដែរ តែគាត់មកលេងកូនគាត់ ។ គាត់នៅស្រុកកំណើត ។

ដានី ៖ ស្រុកកំនើតនៅ?

សាន ៖ ៨មុំ ។

ដានី ៖ នៅ៨មុំ ។ តែកូនលោកតាទាំង៤ គាត់នៅនេះ?

សាន ៖ អត់ទេ នៅ៨មុំ នៅនេះមកនេះតែ១ មកតែ១ ។

ដានី ៖ នៅតែមួយទេ ។ លោកតាបែកគ្នាជាមួយគាត់ តាំងពីអង្កាល់?

សាន ៖ ៧០ ។

ដានី ៖ ឆ្នាំ៧០ បែកជាមួយ?

សាន ៖ អឺ!

ដានី : ចុះលោកតាពេលនឹង លោកតាធ្វើយុវ័ន្តតាំងពីឆ្នាំ៧០ តែលោកតាមានប្រសាសន៍មិញថា លោកតាធ្លាប់បានចូលបដិវត្តតាំងពីឆ្នាំណាមក?

សាន : ចូលបដិវត្តអានឹងតាំងពីបារាំងទៅស្រុក យើងមានការរៀបរយក្នុងស្រុករបស់យើង មានការចូលក្នុងចំណុច ដូចក្មួយនិយាយមិញចឹងយើងមានគណៈបក្សច្រើនចឹង ។ ចឹងយើងនៅក្នុងគណៈបក្សផ្សេងចឹង ។ គណៈបក្សដូចសម្តេចគណៈរាជានិយមអីចឹង ហើយខាងគណៈបក្សតស៊ូនឹងវាមានតាំងពីហនុមាន ស្អីៗខ្លះខ្ញុំភ្លេចអស់ហើយ ១៨នោះ ។

ដានី : ប៉ុន្តែលោកតាចូលជាមួយខាង?

សាន : គណៈបក្សប្រជាជន ។

ដានី : គណៈបក្សប្រជាជនចូលតាំងពីឆ្នាំណាមក?

សាន : ហ៎ា?

ដានី : ចូលតាំងពីឆ្នាំណា ដែលលោកតាចូលជាមួយគណៈបក្សប្រជាជន ក្រុមប្រជាជន?

សាន : ចាំមើលភ្លេចៗអស់ហើយ វាអត់មានឯកសារវាមិនងាយចាំទេ ហើយយើងក៏អត់ចងក្រងទុក ។

ដានី : ប៉ុន្តែរដ្ឋប្រហារឆ្នាំ៧០ ដូចថាលោកតាចូលតាំងពី?

សាន : អត់មានទេ មុន អ្នកធ្វើនឹងវាធ្វើជាប់ចឹង ឈប់សង្គ្រាមពី បើគិតតាមឈប់សង្គ្រាម បានដឹង ។

ដានី : ឈប់សង្គ្រាម?

សាន : ឈប់សង្គ្រាមសន្និសិទហ្សឺណែវឆ្នាំ១៩៥៤ ។

ដានី : ៥៤ បាទ!?

សាន : បាទ! អានឹងវាជាប់ទៅ ហើយយើងរៀបចំស្រុកទេសរបស់យើងៗរៀបចំអ្នកដឹកនាំនៅក្នុងនឹង ។ ឆ្នាំ១៩៥៤នឹង ខ្ញុំចូលក្រុបខ័ណ្ឌយុវ័ន្តនឹងហើយ ។

ដានី : បាទ! ក្រុបខ័ណ្ឌយុវ័ន្តនឹង បានន័យថាយើងក្រុបខ័ណ្ឌរបស់សម្តេច?

សាន : បាទ!

ដានី : ប៉ុន្តែលោកតា?

សាន : វានៅក្នុងក្រុបខ័ណ្ឌនឹង ដូចយើងនៅរាល់ថ្ងៃឃើញទេ នៅជាមួយសម្តេច ហ៊ុន សែន ប៉ុន្តែក្មួយឯងនៅក្នុងគណបក្សហ៊្វុនស៊ីប៉ិចគណបក្សអីចឹង គណបក្សប្រជាជនជាគណបក្សសម្តេច ហ៊ុន សែន តែគណបក្សហ៊្វុនស៊ីប៉ិច ជាគណបក្សរបស់សម្តេចរណរិទ្ធិ ហើយគណបក្សស្អីៗទៀតវានៅក្នុងនោះវាមានគណបក្សច្រើនដូចគ្នាចឹង ។

ដានី ៖ ចឹងបានន័យថាលោកតាចូលគស៊ូតាំងពីឆ្នាំ៥៤មក ជាមួយគណបក្សប្រជាជន?

សាន ៖ បាទ! តាំងពីនៅយុវ័ន្តនឹង យុវ័ន្តនឹងបំផុសការងារតស៊ូចូលក្នុងនឹង ។

ដានី ៖ កាលនឹងអ្នកណាដូចថាយើងចូលទៅជាមួយពីណា?

សាន ៖ គាត់ស្លាប់ ។

ដានី ៖ ពីណាខ្លះ ដែលដូចមកបំផុសលោកតាឲ្យចូលរួមជាមួយគាត់?

សាន ៖ កាលនឹងគណបក្សប្រជាជននឹង គឺឈ្មោះអីទេធ្វើប្រធានភ្លេចបាត់ គាត់ណុប ប៊ូដាន់ ។

ដានី ៖ ណុប ប៊ូដាន់?

សាន ៖ បាទ! គណបក្សប្រជាជន ។

ដានី ៖ កាលនឹងគណបក្សប្រជាជនមានក្រុមសំខាត់ និងក្រុមជំហរ ណុប បូដាន់គាត់ក្រុមជំហរ គាត់តំណាងអ្នកចូលរួមបោះឆ្នោត ។

សាន ៖ អានឹងយើងស្គាល់តាមចឹង ។

ដានី ៖ ណុប បូដាន់, នង សួត ចឹង?

សាន ៖ នង សួត ខ្ញុំអត់ស្គាល់គាត់ទេ ។

ដានី ៖ អត់ស្គាល់គាត់ទេ?

សាន ៖ ធ្លាប់ឮតែឈ្មោះ ។

ដានី ៖ ប៉ុន្តែលោកតាស្គាល់ ណុប ប៊ូដាន់ ស្គាល់ច្បាស់អត់?

សាន ៖ ស្គាល់ច្បាស់នៅស្រុកជាមួយ ។

ដានី ៖ ស្រុកជាមួយគ្នា?

សាន ៖ បាទ! ចឹងបានគាត់មករៀបរយៗយុវ័ន្ត ។ ចឹងបានយុវ័ន្តវានៅក្នុងរដ្ឋាភិបាល ប៉ុន្តែក្រប ខ័ណ្ឌគណបក្សវានៅខាងនេះ ។

ដានី ៖ ចុះពេលបោះឆ្នោតឆ្នាំ៥៥ លោកតាមានឈរឈ្មោះធ្វើតំណាងអីដែរអត់?

សាន ៖ អត់ទេ ។

ដានី ៖ ព្រោះយើងឆ្នាំ៥៥ យើងបោះឆ្នោត?

សាន ៖ បាទ! អត់មាន ។

ដានី ៖ អត់ទេ ដូចថា?

សាន ៖ តំណាងយុវជននឹងហើយ ។

ដានី ៖ ដូចថាតំណាង ដូចថាលោកតាត្រូវឈរឈ្មោះក្នុងស្រុក ធ្វើជាតំណាងនៅក្នុងស្រុក ឬក៏ តំណាងខេត្ត លោកតាអត់?

សាន ៖ អត់ទេ ខ្ញុំតំណាងយុវជននឹង ។

ដានី ៖ តំណាងយុវជននៅ?

សាន ៖ បាទ! ក្នុងស្រុក ។

ដានី ៖ តែកាលនឹងឆ្នាំ៩៥ គណបក្សប្រជាជនមិនបោះឆ្នោតចាញ់ គណបក្សសង្គមរាស្ត្រនិយមឈ្នះ ។ ប៉ុន្តែលោកតាមាននៅតែ?

សាន ៖ នៅតែក្របខ័ណ្ឌ យើងធ្វើតែការងារធម្មតា អត់មានដែលរួចថារកចាញ់យកឈ្នះទៅប្រឡងទៅធ្វើជាមួយក្រុមគណបក្សផ្សេងអត់មាន ។ ពេលនឹងគេនិយាយចឹងម៉ង ។

ដានី ៖ ចុះខាងសម្តេចគេអត់មាន រករឿងលោកតាអត់មានអី ដែលលោកតាខាងគណបក្ស ផ្សេងឈរឈ្មោះបោះឆ្នោត?

សាន ៖ អត់ដឹង ។

ដានី ៖ អត់ដឹង?

សាន ៖ អឺ!

ដានី ៖ យើងសំងាត់?

សាន ៖ អឺ! បើយើងនៅយុវ័ន្តក្របខ័ណ្ឌនៅសម្តេច របស់រដ្ឋាភិបាលៗគ្រប់គ្រងតែផ្នែកយោធានឹងទៅ អាផ្នែកនយោបាយ ។

ដានី ៖ បាទ! ចុះលោកតាដូចក្រុមសំងាត់ ដូចជាក្រុមរបស់ទូសាមុត ដូចក្រុមរបស់សៀវ ហេងក្រុមតានួន ជា មានដែលចូលរួមប្រជុំជាមួយគាត់អត់ កាលពី?

សាន ៖ អត់ៗមានទេ បាទ! សម័យនឹងមានតែតំណាងខាងអ្នកកាសែតនឹងមក គណបក្សប្រជាជននឹងមក ក៏ខ្ញុំនៅយុវ័ន្តអត់ទាន់ធ្វើបាន មិនទាន់គេជួយចាត់ចែងការងារខាងរដ្ឋបាលនឹងវាអត់មានអី ដូចយោធាចឹង វាធ្វើចឹង ។ យោធាវាអត់មានចូលខាងគណបក្សណាអត់ទេ ។

ដានី ៖ អត់ទេ?

សាន ៖ អត់ទេ ប៉ុន្តែបើគេរៀបរយបានយុវ័ន្តនឹងចូលមកក្នុងគណបក្សណាៗ អានឹងវាមានផ្នែករបស់គេ តែដូចពួកខ្ញុំនឹង អានឹងម៉ាស្រុកអត់មានគណបក្សណាៗ ព្រោះអានឹងជាប្រដាប់អាវុធរបស់គេផ្សេងៗចឹងមកអត់មាន ។

ដានី ៖ ចឹងដល់ពេលរដ្ឋប្រហារឆ្នាំ៧០នឹងយ៉ាងម៉េចទៀតទៅ ព្រឹត្តិការណ៍ដូចថា យើងពេលរដ្ឋប្រហារយើងប្រែប្រួល ហើយលោកតាយ៉ាងម៉េចទៅ?

សាន ៖ ទៅចូលព្រៃ ចេញមកព្រៃអស់ ។

ដានី ៖ ឆ្នាំ៧០នឹង?

សាន ៖ ប្រដាប់អាវុធនឹង អស់៦០ប៉ុន្មាននាក់ ៦០ជាង ៨០ជាង អស់ជិតជាងពាក់កណ្ដាល ក្មេងៗមកទាំងអស់ ចាស់ៗអត់ ។

ដានី ៖ អ្នកដូចថាពេលដែលនឹង លោកតារត់មកព្រៃនឹង លោកតាដឹកនាំកម្លាំង?

សាន ៖ មានមេដឹកនាំខាងលើៗទៀតមាន តែគាត់ស្លាប់ ។

ដានី ៖ ពីណាគេដែលដឹកនាំ?

សាន ៖ ឈ្មោះ បងនោ ។

ដានី ៖ ពីណាទៀត?

សាន ៖ នៅកន្លែងខ្ញុំដែលមេជាមួយខ្ញុំ មានបងនោ ។

ដានី ៖ ឈ្មោះ នោ នឹងគាត់មេ?

សាន ៖ បាទ!

ដានី ៖ បន្ទាប់មកលោកតា?

សាន ៖ បាទ! មេជាមួយគ្នារង ។

ដានី ៖ មេគាត់ប្រធាន លោកតារង?

សាន ៖ បាទ!

ដានី ៖ កាលនឹងយើងចូលព្រៃ យើងរត់ពីកន្លែងណាទៅកន្លែងណាទៅ ដូចថាយើង?

សាន ៖ រត់ពី គ្រាន់តែចេញពីភូមិនៅតាមព្រៃ ។

ដានី ៖ បានន័យថាយើងចេញពី៨មុំនឹង យើងនៅតាមព្រៃម្ដុំៗនឹងដែរ?

សាន ៖ ដើរតាមព្រៃ នៅភ្នំជិតៗឱរ៉ាល់អី ។

ដានី ៖ កាលនឹងលោកតាទៅតែម្នាក់ឯងទេ ដូចជាគ្រួសារ?

សាន ៖ អត់ទេ គ្រួសារអត់ទៅទេ ។

ដានី ៖ អត់ទៅៗម្នាក់ឯង?

សាន ៖ ទៅតែប្រុសៗ ។

ដានី ៖ ក្នុងចំណោមយុវន្ដទាំងអស់នឹងទៅប្រហែលជាប៉ុន្មាន ដូចថាទាំងអស់វាមាន១០០?

សាន ៖ ១៨០ ។

ដានី ៖ ១៨០ ទៅចូលព្រៃប៉ុន្មានទៅ?

សាន ៖ ៦៨ ។

ដានី ៖ ៦៨នាក់?

សាន ៖ បាទ!

ដានី ៖ ចូលឆ្នាំ៧០នឹងម៉ង?

សាន ៖ បាទ! ៦៨ទាក់នឹង នៅតែងាប់ជិតអស់ អត់សល់ទេ នៅសល់តិច ដល់ច្បាំងពេលនឹងអស់ ។

ដានី ៖ ដល់ពេលនឹង យើងចូលទៅ បានន័យថាយើងតស៊ូ ច្បាំងជាមួយទាហាន?

សាន ៖ ទាហាន ។

ដានី ៖ កាលនឹងយើងមានទាក់ទងជាមួយក្រុមអីខាងក្រៅយ៉ាងម៉េចទៅ?

សាន ៖ អត់ៗដឹង ។

ដានី ៖ អត់ដឹង?

សាន ៖ ខាងក្រៅអីអត់ដឹង តែបាយទឹក គ្រាប់រំសេវ គឺខ្លួនឯងម្ចាស់ការ អត់មាន ។

ដានី ៖ ចេញពេលរដ្ឋប្រហារថ្ងៃ១៨នឹង ចេញថ្ងៃនឹង ឬក៏ចេញក្នុងពេលណាទៅ?

សាន ៖ ចេញពេលរដ្ឋប្រហារនឹង ។

ដានី ៖ ចេញពេលរដ្ឋប្រហារនឹង ចេញបណ្តោយ?

សាន ៖ រដ្ឋប្រហារៗ ដណ្តើមអាវុធយកចូលព្រៃនឹងហើយ ។

ដានី ៖ កាលនឹងយើងមានប្រើអាវុធអីខ្លះទៅ?

សាន ៖ អាវុធពួកយុវ័ន្តវាមានកាំភ្លើងមុខកាត់ វាមានតាមផ្នែករបស់គេខ្លះមានមុខសេ ខ្លះមានមុខកាត់ដូចពួកស្រុកខ្ញុំមានមុខកាត់ ។ ហើយនៅខាងផ្សេងៗ មានមុខសេរមានអីខ្លះ មានអាកាំភ្លើងអាមេរិចនឹង អាមុខសេ មានកាំភ្លើងអាមេរិចកាច់ម៉ាគ្រាប់ៗ ១០

ដានី ៖ ចឹងចាប់ពីឆ្នាំ៧០នឹង លោកតាបែកគ្រួសារ?

សាន ៖ បាទ!

ដានី ៖ ដល់ពេលយើងចូលទៅក្នុងព្រៃនឹង យើងមិននៅជិតៗភូមិនឹងដែរ?

សាន ៖ អត់នៅជិតបានទេ ។

ដានី ៖ នៅកន្លែងណាទៅ ពេលដែលចូលព្រៃ?

សាន ៖ នៅភ្នំ ។

ដានី ៖ ភ្នំណា?

សាន ៖ នៅភ្នំពីស នៅភ្នំទិវ៉ាល់ ។

ដានី ៖ ភ្នំពីស ភ្នំទិវ៉ាល់?

សាន ៖ បាទ!

ដានី ៖ ចុះគ្រួសារអីអត់ដែលមកជួប លោកតាអត់ដែលទៅជួប?

សាន ៖ អត់ទេ ទៅជួបម៉េច គេបែកដាច់ យើងរស់នៅដោយនៅព្រៃ ។

ដានី ៖ ចឹងលោកតាចូល៦៨នាក់នឹង យើងមាន អត់មានទាក់ទងជាមួយ ព្រោះកាលនឹងថ្ងៃ១៨ មិនា ឆ្នាំ៧០នឹង សម្ដេចមិនអំពាវនាវពីទីក្រុងប៉េកាំងមកថា ឲ្យបងប្អូនកូនចៅចូលព្រៃម៉ាគី ដើម្បី?

សាន ៖ យើងដឹងទាំងអស់ មែនថាអត់ដឹងទេ ដឹងទាំងអស់ ដែនការអីណាគេធ្វើរដ្ឋប្រហារអីណា អ្នកធ្វើការដឹងទាំងអស់ដូចខ្ញុំអីដឹងទាំងអស់ ។ ប៉ុនតាំងពី ដាប ឈួន ត្រៀមធ្វើរដ្ឋប្រហារ សម្ដេចមុននឹងខ្ញុំដឹងទាំងអស់ ។ សង្គ្រាមយើងមិនមែនទើបតាំងពីឆ្នាំ៧០នឹងទេ ដាប ឈួន ធ្វើរដ្ឋប្រហារក៏ខ្ញុំដឹង ហើយក្រុមយុវ័ន្តនឹងក៏ដឹង រៀនសូត្រដឹងទាំងអស់ ។ អានឹងដូចសាលា រៀនចឹង តែលោកគ្រូយកមកផ្សាយគេដឹង ។

ដានី ៖ តែលោកតា ពីឆ្នាំ៧០នឹង យើងតស៊ូអីចឹង នៅ៦០នាក់នឹងយើងយ៉ាងម៉េចទៅ យើង វិវត្តន៍?

សាន ៖ វិវត្តន៍ការលំបាកនឹងជួបអត់បាយ គ្រួនចាញ់ ថ្នាំពេទ្យអីណា ថ្នាំសន្លប់ ប៉ុនបាយទឹកគ្មាន អ្នកណាគេផ្គត់ផ្គង់ ។ ហើយនៅដូចជិតព្រំដែនថៃ នៅជិតខាងថៃឃួនចឹងអត់មានទេ នៅ ខាងកណ្ដាល ។

ដានី ៖ ប៉ុន្តែក្នុងនឹង កាលនឹងគេមានបង្កើតភូមិភាគអី?

សាន ៖ អត់កាត់តាមស្រុក មានតែស្រុក អត់មានបង្កើតភូមិភាគ ។

ដានី ៖ តស៊ូនៅកន្លែងពីភ្នំឱរ៉ាល់ដល់ពេលណាទៅ លោកតានៅនឹងដល់ពេលណាទៅ ?

សាន ៖ ហ៊ឺ! អត់នៅទេ នៅបែកគ្នាទៅអស់ហើយ ដូចបែកបន្តបន្ទាប់ ចេះចុះតាមភូមិរៀបចំបន្តៗ រហូត ។ ដើម្បីរកម្ហូបបាយទឹកៗអីបានយើងថា យើងពង្រីកកម្លាំងៗទាក់ទងពលរដ្ឋទៅតាម ភូមិ ចុះទៅតាមភូមិ ។ ពិតមែនតែទិសដៅថានៅភ្នំឱរ៉ាល់ ភ្នំពីស ប៉ុន្តែអានេះជាគោលទេ ចឹងយើងនៅភូមិព្រំដែននឹង បានៗបាយហូប ។ បើយើងនៅភ្នំម៉េចបានបាយហូប ។ យើង ទៅធ្វើការជាមួយប្រជាពលរដ្ឋ ។

ដានី ៖ ចឹងក្នុងនឹងយើងត្រូវតែចុះទៅអប់រំប្រជាជន?

សាន ៖ អប់រំប្រជាជន ហៅថាការងាររសំងាត់ណា បានទៅរើទាហានបាន មកពីមានពលរដ្ឋទៅ ស៊ើបមើលទាហានអីចឹង ប៉ុស្តិ៍ណាតូចដាក់ចឹងទៅ កន្លែងណាទាហានតូចដាក់ចឹងទៅប្រហែល កន្លែងណាយើងចលនាបាន យើងអូសយកមក ។

ដានី ៖ ចុះលោកតាកាលនឹងចុះទៅខាងណាទៅ?

សាន ៖ បាទ?

ដានី : យើងទៅចលនាប្រជាជន?

សាន : ចុះទៅពាម ៨មុំនឹង ទៅវាលប៉ុន ដល់៧១បានខ្ញុំទៅតាកែនកោះស្លា ។

ដានី : ៧១ ទៅខាងតាកែនកោះស្លា?

សាន : បាទ! អានឹងបានយួនឡើងមកហើយ យួនឡើងពីក្រោមមកដល់នឹង វៃជាមួយយួនតាកែន កោះស្លា វៃព្រីង ស្រែក្រសាំង ។

ដានី : ភូមិព្រីង ស្រែក្រសាំង?

សាន : បាទ!

ដានី : នៅណាទៅ នៅតាកែនកោះស្លា?

សាន : នៅស្រុកភ្នំស្រួច ។

ដានី : នៅស្រុកភ្នស្រួច?

សាន : បាទ! អានឹងគេចែកគ្នាចឹង ខាងនោះទៅដឹកនាំនៅខាងនោះ ។

ដានី : លោកតាមានតួនាទីអីគេកាលនឹង?

សាន : នាទីជាកង មុនដំបូងតិចនឹង បំលែង៣-៤-១០នាក់ ដែលគេថាចោរព្រៃវាត្រូវហើយ បើយើងវាមានកម្លាំងតិចៗ ទាល់បង្កើតកម្លាំងនៅនឹងទៅបាន១០០ បានខ្ញុំចុះដល់មកនេះ ស្លាបលែង ។

ដានី : ស្លាបលែង?

សាន : ១៨០ ១៧០នាក់ ដល់ពួកខ្ញុំមានចលនាទាហានម៉ាកន្លែងបាន កន្លែងនៅស្រែក្រសាំងនឹង ទាហានកាលនឹងពិបាកនិយាយ ទ្រាំទ្រនឹងការលំបាក អត់បាយអត់ទឹក ផាប់ថ្ងៃនឹងផាប់ទៅ ផាប់ស្អែកផាប់ទៅ ។

ដានី : កាលនឹងចូល៧១ ដល់ឆ្នាំ៧១?

សាន : ៧១ ។

ដានី : កាលនឹងលោកតាកសាងកម្លាំងបាន១០០ជាង?

សាន : បាទ!

ដានី : ១៧០?

សាន : ១៧០នាក់ ។

ដានី : នៅខាងស្លាបលែងកាលនឹង?

សាន : បាទ! នៅស្លាបលែងខ្លះ នៅឃុំអូរនឹងខ្លះ យកកាំភ្លើងពីកន្លែងក្រសាំងទៅបាន៤៨ដើម ។ កាំភ្លើងអត់មាន យើងយកបានប៉ុណ្ណា យើងយកបានប៉ុណ្ណាស្រេចខ្លួនឯង ។

ដានី ៖ ប៉ុន្តែកាលនឹងយើងដូចថាយើងទៅកន្លែងចឹង យើងរៀបចំភូមិឃុំ យើងរៀបចំអីជារបស់យើង?

សាន ៖ បាទ! រៀបចំជាកម្លាំង អត់ទាន់រៀបចំជាភូមិឃុំអីទេ អត់ទេ កម្លាំងឈ្លប កម្លាំងជួយការងារៗ ដូចអ្នកស្រុកចេញទៅព្រៃចឹង យើងរៀបចំជួយរកបាយរកទឹក រកកន្លែងអីចឹង ។

ដានី ៖ ឲ្យធ្វើស្រែធ្វើអី?

សាន ៖ អត់ទេ អត់មានធ្វើទេ ។

ដានី ៖ គ្រាន់រៀបចំកម្លាំង?

សាន ៖ រៀបចំកម្លាំងឲ្យជួយចិញ្ចឹមយើងណា ។

ដានី ៖ ឲ្យជួយចិញ្ចឹមយើង?

សាន ៖ បាទ! ចិញ្ចឹមអ្នកតស៊ូ បើយើងរៀបវាទៅជាយើងប៉ះពាល់ដល់ចោរ ដល់ធ្វើចោរ ធ្វើឈ្លួញ មិនប្រជាជនអត់គាំទ្រ ។ ចឹងយើងធ្វើជាអ្នកតស៊ូបានគេគាំទ្រ អ្នក...គេយកបាយយកអង្ករឲ្យគេ ។

ដានី ៖ ចឹងឆ្នាំ៧១លោកតានៅខាងស្វាយលែង បន្តទៀតទៅណាទៀត បន្តពី៧១?

សាន ៖ ៧២ ខ្ញុំទៅនៅតាកែវ ខាងជើងតាកែវ ។

ដានី ៖ ខាងអីគេ ខាងជើងតាកែវ?

សាន ៖ ស្រុកព្រៃកប្បាស ។

ដានី ៖ ខាងព្រៃកប្បាសវិញ?

សាន ៖ បាទ!

ដានី ៖ ចុះមុនៗម៉េច លោកតាមានប្រសាសន៍ថាទៅខាងតាកែនកោះស្លា នឹងទៅឆ្នាំណា?

សាន ៖ អានឹង៧១នឹងឯង ទៅដល់នឹង ចុះយើងដើរពេញតែដីម្តុំនឹងខាងលើនឹងដើរទៅព័ទ្ធខាងជើងម្តុំនែក!ភ្លេចឈ្មោះអស់ហើយ យូរពេក ។ ដើរពេញសព្វតែដី កាលនោះទាហានគ្មានហ៊ាននៅក្រៅប៉ុន្មាន ដែលនៅតិចៗចាប់ជីវិតយក ។

ដានី ៖ ចឹងលោកតា ចុះខាងកណ្តាលស្អីង កណ្តាលអីលោកតាដើរ?

សាន ៖ អត់ទេ ។

ដានី ៖ ហេតុអី?

សាន ៖ ខ្ញុំអត់ដែលទៅដល់នឹង ខ្ញុំទៅដល់តែត្រឹមទន្លេបាទី ។

ដានី ៖ ទន្លេបាទី?

សាន ៖ បាទ! ព្រៃស្លាៗ ទន្លេបាទី ខាងកើតទន្លេបាទីនឹង ។

ដានី ៖ គួស...អត់ដែលទៅដល់ទេ?

សាន ៖ អត់ទេ អត់ដែលគ្រប់គ្រង ។

ដានី ៖ បឹងខ្យាង បឹងអីអត់?

សាន ៖ អត់ៗដែរ ។

ដានី ៖ ខាងកណ្តាលស៊ឹងគេគ្រប់គ្រងផ្សេង?

សាន ៖ បាទ! កម្លាំងគេផ្សេង ។

ដានី ៖ ប៉ុន្តែយើងទាក់ទងគ្នា យើងស្គាល់គ្នាដែរតើ?

សាន ៖ ស្គាល់ ។

ដានី ៖ កាលនឹងខាងកណ្តាលស៊ឹងពីណាគេ?

សាន ៖ កណ្តាលស៊ឹងភូមិភាគកណ្តាលៗវាមាន តាទាញ អឺ!ភ្លេចគ្នាអស់ហើយ តាទាញ ១០១ គ្នាគេ មិនដឹងឈ្មោះគេអី និស្សិតចេញពីក្រុងដែរ ។ ពួកនឹងច្រើននិស្សិតចេញពីក្រុង ។ ១០១នឹង សុទ្ធវៃចោលដែរនឹង ។

ដានី ៖ ចឹងលោកតាចេញជំនៀរពីខាងនឹង មក៧២នឹងមកខាងព្រៃកប្បាសវិញ?

សាន ៖ បាទ!

ដានី ៖ នៅព្រៃកប្បាសនៅម្តុំណាទៅ?

សាន ៖ ព្រៃកប្បាសនៅខាងជើងតាកែវ ខេត្តតាកែវ ។

ដានី ៖ បាទ! ខ្ញុំស្គាល់ព្រៃកប្បាស ប៉ុន្តែម្តុំ?

សាន ៖ ....អត់មានទេ ។

ដានី ៖ យើងដើរចលនា?

សាន ៖ បាទ! ដើរចុះដើរឡើង ។

ដានី ៖ ពីខាងណាទៅ?

សាន ៖ ពីខាងកើតថ្នល់លេខ២ ។

ដានី ៖ ខាងកើតថ្នល់លេខ២ ។ រត់ចូលក្នុងព្រៃ?

សាន ៖ បាទ! រត់ចូលព្រៃ ។

ដានី ៖ ចលនានៅខាងនឹងរហូតដល់ពេលណាបានចេញមកវិញ?

សាន ៖ ខ្ញុំនៅម៉ាឆ្នាំ ៧៣មកវិញ ។

ដានី ៖ ៧៣មកខាងណាវិញ?

សាន ៖ ៧៣ មកវៃពីខាងលិចភ្នំពេញ ។

ដានី ៖ ៧៣ មកវិញពីខាងលិចភ្នំពេញវិញ?

សាន ៖ បាទ!

ដានី ៖ ខាងណា ខាងលិចភ្នំពេញ?

សាន ៖ ខាងទួលវៀង បែកចាន ខាងជើងបែកចាន ។

ដានី ៖ ដល់ពេលយើងមកនឹងវិញ យើងរៀបចំជាកងទ័ព ជាកងពល ជាអីៗ?

សាន ៖ ជាកងពល ។

ដានី ៖ ចឹងហ៎?

សាន ៖ ចេញពីកងពលហើយ ចេញពីព្រៃកប្បាសមក១៨០ យកមកផ្គុំនឹងគេរៀបឲ្យថែមទៀត ទៅជាកងពលតូច ។

ដានី ៖ កាលនឹងពេលឆ្នាំ៧៣យើងរៀបបានជាកងពលតូចហើយ លោកតា?

សាន ៖ បាទ!

ដានី ៖ កងពលតូចលេខប៉ុន្មានទៅ?

សាន ៖ ខ្ញុំលេខ១៩ ។

ដានី ៖ កងពលតូចលេខ១៩?

សាន ៖ បាទ!

ដានី ៖ មានកម្លាំងប៉ុន្មានកាលនឹង?

សាន ៖ ៣វរៈសេនាតូច ម៉ាវរៈសេនាតូច៣០០នាក់ ។

ដានី ៖ ចឹង?

សាន ៖ បាទ!

ដានី ៖ ចឹងមិនមែនវរៈសេនាធំទេ កងពលតូច?

សាន ៖ បាទ! កងពលតូច វានឹងវរៈសេនាធំហើយ ។

ដានី ៖ កងពលតូចនឹងគេហៅវរៈសេនាធំដែរ?

សាន ៖ បាទ! វរសេនាធំ ។

ដានី ៖ ចឹងលោកតាគ្រប់គ្រង៣វរៈសេនាតូច?

សាន ៖ បាទ!

ដានី ៖ ហើយវរៈសេនាតូចលេខ១០ប៉ុន្មាន?

សាន ៖ ១៩ ។

ដានី ៖ ១៩ ចុះកងពលលេខប៉ុន្មានទៅ កងពលធំ?

សាន ៈ លេខ៩ ។

ដានី ៈ កងពលធំលេខ៩?

សាន ៈ បាទ!

ដានី ៈ ចឹងពាកងពលតូចបានៗម៉ាកងពលធំ?

សាន ៈ បាទ!

ដានី ៈ ចឹងលោកតាកងពល១១៩?

សាន ៈ បាទ!

ដានី ៈ កងពលប៉ុន្មានទៀត ម៉ាកងពលលេខ៩ មានប៉ុន្មានវរៈ?

សាន ៈ កាលដើមឆ្នាំ៧៣នឹង គេដូរពាវរៈសេនាធំ មានលេខ៧ គេដូរមកទម្ងាក់វិញ គេកែងដាក់កងវរៈវិញហើយណា គេដាក់មកកងពលតូចនឹង មានលេខ៧ មានលេខឃ៣ ឃ៤ ឃ៥ ឃ៦ ។

ដានី ៈ ប្រធាន-ឃ កាលនោះ?

សាន ៈ បាទ! ហ្នឹងហើយ នៅចាំអានឹង អត់ចាំ ។

ដានី ៈ ចឹង៣-ឃ?

សាន ៈ បាទ!

ដានី ៈ បានម៉ា-ង?

សាន ៈ បាទ!

ដានី ៈ ង នឹងកងពលហើយ?

សាន ៈ បាទ!

ដានី ៈ ប៉ុន្តែលោកតាកាលនឹងប្រធាន ឃ?

សាន ៈ បាទ!

ដានី ៈ ចុះប្រធាន ឃ ផ្សេងទៀតឈ្មោះអីទៅលោកតា?

សាន ៈ ឈ្មោះ មិត្តប្រាក់ ។

ដានី ៈ ឈ្មោះប្រាក់?

សាន ៈ បាទ!

ដានី ៈ មួយទៀត?

សាន ៈ ម៉េង ។

ដានី ៈ ឈ្មោះ ម៉េង?

សាន ៖ បាទ!

ដានី ៖ ចុះប្រធាន ង?

សាន ៖ ប្រធាន ង ងាប់អស់ហើយ ពួកនឹង សុទ្ធតែឈ្មោះ ណាត ។

ដានី ៖ ឈ្មោះ តាណាត?

សាន ៖ អឺ! ណាត ហើយខ្មោចប៊ិតនឹង ។

ដានី ៖ តាណាត អូ! សំ ប៊ិត?

សាន ៖ បាទ! ប្រធានវរៈសេនាធំ ប្រធានកងពល ។

ដានី ៖ ប្រធានកងពល តាប៊ិត ហើយតាណាត?

សាន ៖ បាទ!

ដានី ៖ តាណាតនឹងគាត់ស្លាប់ពីអង្កាល់?

សាន ៖ ហ៎! អត់ដឹងទេ បែកគ្នាអស់មក ។

ដានី ៖ មិនមែនតាណាត កងពល១១ មិនមែនទេ?

សាន ៖ ហ្នឹងហើយ ។

ដានី ៖ តាណាតនឹង?

សាន ៖ បាទ!

ដានី ៖ តាណាត ខ្ញុំធ្លាប់ឮឈ្មោះ ព្រោះខ្ញុំធ្លាប់ទៅសម្ភាសន៍ខាងនោះ មានខាងកងពល១២ ហើយគាត់ជាប្រធានកងពល១២ ខាងនោះវាមានកងពល១១ ១២ ហើយក្រោយមកគេបង្កើតជាកងពល៧០៣ ។

សាន ៖ មិនមែនទេ កងពល៧០៣នៅខាងនោះវិញ ៧០៣ បន្ទាយមិញនោះ៧០៣ ខ្ញុំនៅចាំ ។ កងប៉ុន្មានទេ ខ្ញុំភ្លេចអស់ហើយ ។ ប៉ុន ណាត នឹងនៅខាងនេះ ហើយក្រោយឡើងគេដូរខ្ញុំមកកងពលទី១វិញ ។

ដានី ៖ មកកងពលទី១វិញ?

សាន ៖ បាទ! ៧៨នឹងមកខាងនេះវិញ ។

ដានី ៖ មកខាងណា?

សាន ៖ មកខាងជើងផ្លូវលេខ៤ ។

ដានី ៖ ខាងជើងផ្លូវលេខ៤ មកខាង?

សាន ៖ អានឹងមុំវត្តភ្នំៗមុំអឺមក យើងខេត្តផ្ន ខាងត្បូងខេត្តផ្នមកលង្វែក ខាងលិចលង្វែក មកតាមព្រៃ អានឹងវាពិបាកនិយាយ ។

ដានី ៖ ចឹងបើយើងពេលមកខាងកងពលលេខ១នឹង មកជាមួយខាងកងពលភូមិភាគឧត្តរវិញ?

សាន ៖ អត់ទេ ឧត្តរគេមានកងពលទី១ រហូតដល់ទីប៉ុន្មានទេ ខាងភូមិភាគបស្ចិមនេះយើងមានទី ១៧នឹងមកខាងជើងផ្លូវលេខ៤ ។

ដានី ៖ កាលនឹងគេហៅភូមិភាគពិសេស?

សាន ៖ មិនមែនទេ ។

ដានី ៖ មិនមែន គេហៅភូមិភាគអីវិញ?

សាន ៖ បាទ! ភូមិភាគពិសេសវានៅកណ្តាល ។ នៅពួកមិត្តទាញ ពួករឿនហ្នឹងកងភូមិភាគពិសេស ។

ដានី ៖ សារឿននឹង?

សាន ៖ បាទ! រឿន សាន ។

ដានី ៖ បាទ! ឈ្មោះសារឿន ឈ្មោះសាន ០៥ ០៦?

សាន ៖ បាទ!

ដានី ៖ ហ្នឹងនៅក្នុងភូមិភាគពិសេស?

សាន ៖ បាទ!

ដានី ៖ ចឹងលោកតានៅខាងភូមិភាគបស្ចិមវិញ?

សាន ៖ បស្ចិម ខ្ញុំនៅបស្ចិម ។

ដានី ៖ នៅជាមួយជូ ជេត?

សាន ៖ បាទ!

ដានី ៖ ក្រែងភូមិភាគបស្ចិមនឹងគេបង្កើតក្រោយឆ្នាំ៧៥ ឬក៏មានតាំងពីមុខឆ្នាំ៧៥?

សាន ៖ មានមុន ។

ដានី ៖ មានមុននឹង?

សាន ៖ បាទ! និរតី ហើយនឹងបស្ចិមនឹងគេបង្កើតតាំងពី ។ ដើមគេបង្កើតតែបស្ចិមមួយទេ ហើយក្រោយមកបង្កើតនិរតីមួយទៀត ភូមិភាគនឹង ។ ពីដើមតាជូ ជេត គាត់ទទួលទាំងពីរនឹង ទាំងខាងត្បូង ទាំងខាងជើង ។ ក្រោយមកបានគេកាត់ខាងជើងផ្សេង ខាងត្បូងផ្សេង ។ ខាងជើងតា ជូ ជេត នឹង តាប៉ាល់ ។

ដានី ៖ បាទ! តាជេត តាប៉ាល់?

សាន ៖ បាទ! ហើយខាងយោធា សឿង វាទៅជាគណៈភូមិភាគនឹង៣នាក់នឹង ហើយក្រោយមក ទៅតូចៗ អ្នករង១អីចឹងទៅ រងភូមិភាគ ។

ដានី ៖ ចឹងដល់ពេលលោកតាមកកងពលទី១របស់ភូមិភាគបស្ចិមវិញ?

សាន ៖ បាទ!

ដានី ៖ មកប្រធានកងពល?

សាន ៖ អត់ទេ រង ប្រធានយោធា, សឿង ប្រធាននយោបាយ ។

ដានី ៖ ពីណាសឿង?

សាន ៖ បាទ!

ដានី ៖ តាសឿងប្រធាននយោបាយ លោកតាប្រធានយោធា?

សាន ៖ បាទ!

ដានី ៖ កងពលទី១ ចឹងភូមិភាគបស្ចឹមមានតែម៉ាកងពលនឹងទេ?

សាន ៖ បាទ!

ដានី ៖ ចុះដល់ពេលតាសារឿន តាសាននឹង គាត់កងពលរបស់ភូមិភាគពិសេស?

សាន ៖ ភូមិភាគពិសេស ។

ដានី ៖ ម៉ាកងពលដែរ?

សាន ៖ ២ ។

ដានី ៖ ២កងពល?

សាន ៖ តារឿនផ្សេង តាសានផ្សេង ។

ដានី ៖ តារឿន?

សាន ៖ រឿន ជាមួយ សាន។ មិនមែនរឿននឹង ឈ្មោះសានទេ រឿននឹងជាមួយសាន។ ខ្ពស់ រឿនរៀងដូចក្មួយឯងចឹង ។

ដានី ៖ ខ្ញុំឮធ្លាប់ជួប ឮដឹងថារឿននឹងគាត់ឈ្មោះ០៥ ឈ្មោះលេខរបស់គាត់ចឹង?

សាន ៖ បាទ!

ដានី ៖ ដល់ពេលសាន គាត់០៦?

សាន ៖ បាទ!

ដានី ៖ តែចឹងកងពលគាត់២ផ្សេងគ្នា?

សាន ៖ បាទ! ផ្សេងគ្នា ។

ដានី ៖ រឿនមួយ សានមួយ?

សាន ៖ ទាញមួយ ។

ដានី ៖ អូ! ទាញម៉ាកងពល តារឿន ហើយតាសានម៉ាកងពលជាមួយគ្នា?

សាន ៖ បាទ! ជាមួយគ្នា ចឹងបានគេដាក់លេខគេអូគេលេខ០តែមួយគ្នា ដល់ខាងកើតទន្លេវិញ ភ្លេចហើយឈ្មោះអី ។

ដានី ៖ ខាងកើតទន្លេខាងបូព៌ា?

សាន ៖ បាទ! ខាងបូព៌ាមានកងពលទី១ដែរ ។

ដានី ៖ កងពលច័ន្ទចក្រី?

សាន ៖ អឺ! ច័ន្ទចក្រីទី១ ច័ន្ទចក្រី ឈ្មោះគាត់ឈ្មោះមឿនទេ ។

ដានី ៖ ឈ្មោះមឿន?

សាន ៖ បាទ! ច័ន្ទចក្រី ជាមួយឈ្មោះមឿន ឈ្មោះ សួង រងខាងយោធា ។ ខ្ញុំឃើញម៉ាថ្ងៃ ខ្ញុំអត់ហ៊ានសួរខាងនឹង កាលនឹងនៅក្មេងៗ សួងនឹងក្មេងគាប់ឃើញម្សិលមិញសង្ស័យគាត់មកខាងយោធា ។

ដានី ៖ បើខាងខត្តរ លោកតាស្គាល់ទេ?

សាន ៖ ខាងខត្តរអត់ស្គាល់ទេ ។

ដានី ៖ ខាងខត្តរខាងកងពលទី១ ទី២ ទី៣គេ?

សាន ៖ អត់ៗស្គាល់គេ ។

ដានី ៖ អត់ដែរ ព្រោះខាងខត្តរគេវៃចូលមកខាងភ្នំបាសិត ខាងផ្លូវជាតិលេខ៥ ។

សាន ៖ បាទ! អត់ស្គាល់ ។

ដានី ៖ ខាងផ្លូវជាតិលេខ៥ ផ្លូវជាតិលេខ៦?

សាន ៖ អត់ស្គាល់ទាំងអស់ ។

ដានី ៖ លោកតាស្គាល់តែខាង?

សាន ៖ ខាងត្បូង រៀននៅម៉ាជំនៀរពីត្បូងចេះមក ហើយរឿននឹងគេដកពីកងពលនិរតីមក២នាក់បែក ។

ដានី ៖ តារឿន ស្រុកកំណើតគាត់នៅណា?

សាន ៖ បាទ?

ដានី ៖ ស្រុកកំណើតគាត់?

សាន ៖ នៅឈូក ។

ដានី ៖ នៅឈូក?

សាន ៖ បាទ!

ដានី ៖ ឈូកខាងកំពត?

សាន ៖ បាទ!

ដានី ៖ តារឿន ចុះតាសាន?

សាន ៖ តាសាន អត់ពិបាកមិនដឹងស្រុកគេនៅណា តែសានគេមកពីចិន ។

ដានី ៖ មកពីចិនមក?

សាន ៖ បាទ! គេនិស្សិត គេរៀនដល់ចិន បានដឹង ។

ដានី ៖ ចុះមួយទៀតឈ្មោះតារឿនមួយទៀតដែរ គាត់នៅខាងឱរ៉ាល់ មកនេះ?

សាន ៖ រឿននឹង ស្រុកនៅភ្នំស្រួច រឿនតូច ។

ដានី ៖ បាទ! រឿនតូច?

សាន ៖ បាទ! អានឹងរឿនៗមាន៣ រឿនវែង រឿនគោក រឿនរាំង ។

ដានី ៖ ហើយចឹងកាលពីដំបូងលោកតានៅជាមួយតាណាត តាអីទេ?

សាន ៖ បាទ! នៅជាមួយគ្នា ។

ដានី ៖ តាណាត, តាប៉ិត សំ ប៉ិតនឹង, នៅក្នុងដល់ក្រោយឆ្នាំ៧៤បានបំបែកកងពល?

សាន ៖ បាទ! បំបែកចូលមក ។

ដានី ៖ ចុះតាសឿន គាត់ដំបូងនៅណាដែរ?

សាន ៖ តាសឿន គាត់នៅ១២០ ។

ដានី ៖ គាត់នៅ១២០?

សាន ៖ បាទ! បង្កើតកងទ័ព មុនដំបូង១២០ហ្នឹងកងវរៈជាមួយលោកម៉េតយើងនេះ ស៊ូ ម៉េត ។

ដានី ៖ ស៊ូ ម៉េត?

សាន ៖ បាទ!

ដានី ៖ នៅជាមួយគ្នា តាសឿងនឹង?

សាន ៖ បាទ!

ដានី ៖ តាម៉េតគាត់ ដំបូងគាត់ធ្វើអីកាលនៅជាមួយតាសឿង?

សាន ៖ គាត់ប្រធាននយោបាយ តាម៉េត អឺ!ប្រធានយោធា តាម៉េតប្រធាននយោបាយ ។

ដានី ៖ តាម៉េតប្រធាននយោបាយ តាសឿងនឹងប្រធានយោធា?

សាន ៖ បាទ!

ដានី ៖ តាម៉េតស្រុកកំណើតគាត់នៅណា?

សាន ៖ តាម៉េតនៅស្រែអណ្តូង ។

ដានី ៖ បាទ?

សាន ៖ នៅស្រែអណ្តូង ។

ដានី ៖ នៅស្រែអណ្តូងខាង?

សាន ៖ ចន្ទ្រាលភាល ។

ដានី ៖ ចន្ទ្រាលភាលដែរ?

សាន ៖ អឺ!

ដានី ៖ ចន្ទ្រាលភាល កាលនោះនៅកំពង់ត្រឡាចលើ?

សាន ៖ បាទ!

ដានី ៖ ស៊ូ ម៉េត យើង?

សាន ៖ បាទ!

ដានី ៖ ដល់ពេលក្រោយមក តាសឿងគាត់មកប្រធាន មកខាងនយោបាយ លោកតាយោធា កាលនោះតាម៉េត គាត់ទៅណាវិញ?

សាន ៖ តាម៉េតទៅក្រុង ដែលទៅធ្វើខាងអី គេទៅធ្វើ ។

ដានី ៖ ប៉ុន្តែកាល៧៨យើងមិនទាន់បែកណា?

សាន ៖ នៅទេ គេរៀបចំហើយ ។

ដានី ៖ គេរៀបចំហើយទៅខាងក្រុង?

សាន ៖ បាទ! រៀបចំ ដូចជាកងទ័ពក៏ចឹង អ្នកណាទៅក្រុងគេបែកទៅក្រុង បែកតាំងពី៧៨ ។

ដានី ៖ បាទ! បែក៧៨?

សាន ៖ បាទ!

ដានី ៖ ចុះតាម៉ុត លោកតាស្គាល់?

សាន ៖ ស្គាល់ តាមុត គាត់ភូមិភាគ១និរតី ។

ដានី ៖ តាម៉ុកទេ?

សាន ៖ អឺ! តាមុកប្រធាន ។

ដានី ៖ ចុះមាស មុត?

សាន ៖ មាស មុត គាត់គ្រប់គ្រងខាងស្អីមិនដឹង ខាងនយោបាយអប់រំកងទ័ពផ្សេងៗ ។

ដានី ៖ ចុះលោកតា ខ្ញុំធ្លាប់ជួបតាប៉ូច ស្គាល់តាប៉ូចទេ តាប៉ូចគាត់នៅផ្ទះគាត់នៅជិតវត្តតាំងខ្មៅដែរ តែឥឡូវគាត់នៅអន្លង់វែង?

សាន ៖ ស្គាល់ ។

ដានី ៖ កាលនឹងគាត់ចេញទៅតស៊ូ នៅខាងកណ្តាលស្ទឹង?

សាន ៖ អឺ! ប៉ូចនៅជាមួយតែគ្នានឹង ប៉ុនដល់ពេលនេះទៅបានគេបញ្ជូនទៅនៅ ។

ដានី ៖ តាប៉ូច តាអានអីនឹង?

សាន ៖ បាទ! បញ្ជូនទៅកន្លែងពិសេស កន្លែងភូមិភាគពិសេស ។

ដានី ៖ តាប៉ូចនឹង?

សាន ៖ បាទ! ស្រុកជាមួយខ្ញុំ ។

ដានី ៖ ចឹងលោកតាស្គាល់តាអានដែរ?

សាន ៖ មិនច្បាស់ទេ អាន បើប៉ូចបានច្បាស់ ។

ដានី ៖ ប៉ូចច្បាស់?

សាន ៖ អឺ!

ដានី ៖ បើតាអាន អត់សួរស្គាល់ទេ?

សាន ៖ បាទ!

ដានី ៖ តាអាន គាត់មកកាន់ខាងកណ្តាលស៊ីង គាត់មកគ្រប់គ្រងនៅកណ្តាលស៊ីងនឹង ហើយតាប៉ូច គាត់ កាលខ្ញុំជួបគាត់ៗប្រាប់ថាគាត់គ្រប់គ្រងម៉ាឃុំ ដូចថាគណៈឃោសនាកាលពីជំនាន់ឆ្នាំ ៧០ជាង ។ ដែលលោកតាមានប្រសាសន៍មិញ ថាយើងដើរទៅ ។

សាន ៖ បាទ! ដើរទៅអត់មានទីតាំង ដើរអត់មាន រកទីតាំងកន្លែងណា ភូមិណាអត់ទេ ។ ម៉ាថ្ងៃនៅនឹងទៅ ស្អែកឡើងទៅនៅភូមិនោះ ។

ដានី ៖ ចឹងលោកតាស្គាល់គាត់ច្បាស់ដែរ ស្គាល់តាប៉ូចច្បាស់ដែរ?

សាន ៖ បាទ! ស្គាល់ ជួបសួរមើល ភូមិជាមួយជិតគ្នា ។ តាប៉ូចមិនមែននៅចង្វាលរាលទេ ។

ដានី ៖ អត់ទេ គាត់នៅខាងកំពង់ស្ពឺ ។

សាន ៖ បាទ! ហ្នឹងហើយ ។

ដានី ៖ តាអានបានគាត់នៅចង្វាលរាល ។

សាន ៖ អូ! អានៗល្អិតតិច បាទ! អាន ។

ដានី ៖ គាត់ធ្លាប់បួសនៅវត្តតាំងស្វាយ ។ លោកតាព្រូតែឈ្មោះអត់ដែលឃើញគាត់តាអាន?

សាន ៖ អាន អត់ទេ ។ គ្រាន់ស្គាល់ឈ្មោះ វាអត់ជួបគ្នា បើជួបស្គាល់ តែឥឡូវអត់ទេ ចាស់ៗ ហើយ ។

ដានី ៖ គាត់ល្អិតតើ មាឌល្អិត?

សាន ៖ បាទ! ហ្នឹងហើយមាឌល្អិតស្គាល់ ។

ដានី ៖ ខ្ញុំធ្លាប់ជួបគាត់ដែរ ។

សាន ៖ ហ្នឹងប៉ៃលិន ។

ដានី ៖ ឥឡូវគាត់នៅកំរៀង ។

សាន ៖ ហ្នឹងហើយពួកកំរៀងទៅពីស្រុកខ្ញុំទៅដើង ។

ដានី ៖ គាត់មកពីអន្លង់វែងហើយបានទៅកំរៀង តាប៉ូចគាត់ទៅអន្លង់វែង គាត់ក្រុមប្រឹក្សាឃុំថ្វាត ខ្ញុំទៅជួបគាត់កាលពីឆ្នាំអី ។

សាន ៖ អឺ! ទាហាននៅនឹងសុទ្ធទាហានទៅពីខ្ញុំទាំងអស់ ។

ដានី ៖ អូ! ទាហានទៅពីលោកតាទៅទេចឹង?

សាន ៖ បាទ!

ដានី ៖ ចេញពីជីវពលទៅជាមួយ?

សាន ៖ អត់ទេ ពួកនឹងបង្ហាត់រៀបចំពី៧១ ៧២ទៅរហូត ។

ដានី ៖ អូ! ចឹងទេ ។

សាន ៖ រឿងខ្វាក់ភ្នែកមួយអីនឹងទៅពីកងពល ។

ដានី ៖ រឿនណា?

សាន ៖ រឿននៅខាងលិចអន្លង់វែងនឹង ខ្វាក់ភ្នែកនៅទំនប់ ។

ដានី ៖ ចឹងលោកតាបន្ទាប់ពីឆ្នាំ៧៨នឹង គាត់រៀបចំជាកងពលមួយហើយ កងពលភូមិភាគបស្ចិម ហើយយ៉ាងម៉េចទៀត វៃចូលមក?

សាន ៖ វៃតាមចូលតាមទួលលាភ ។

ដានី ៖ ខាងកងពលរបស់តារឿន ហើយតាសានគាត់ចូលតាមពោធិ៍ចិនតុង?

សាន ៖ ចូលពី ពួកនឹងចូលពីរោងចក្រកែវមក ហើយកងពលរបស់នេះ ចូលកងពលទី២របស់ខាង បស្ចិមនឹង ចូលតាមផ្លូវបំបែកព្រៃព្រីង ចូលតាមរថភ្លើង ។

ដានី ៖ របស់តា?

សាន ៖ របស់ណាតនឹង ។

ដានី ៖ ហើយលោកតាចូលខាងទួកលាភ?

សាន ៖ ហ្នឹង ។

ដានី ៖ កាលវៃគ្នានឹងយ៉ាងម៉េចនឹងលោកតា អាចនៅចាំថាពេលយើងវៃគ្នាមានយ៉ាងម៉េចដូចថា របៀបកាលយើងវៃគ្នាវៃប្រទាញប្រទុងយូរដែរ ឬក៏វៃស្រួលណា យើងចូលមក?

សាន ៖ អូ! ស្រួលណាប្អូនអើយ ផាប់រស់មិនផាយ គេចង់ឲ្យយើង ប៉ុនយើងនិយាយថាដីស្រែ ដីចំការតិចតួចម៉េច គេមិនផាយប្រគល់ឲ្យយើង ដីនេះវាជណ្តើមអំណាចទូទាំងប្រទេស

ហើយម្នាក់ៗ វាសុទ្ធតែដណ្តើមអំណាចគ្នាមួយនឹងមួយ វាស្លាប់រស់នឹងហើយ ។ តែអានឹងវាមកពីអី មកពីចាញ់កម្លាំងទេ ប្រជាជននៅខាងណាច្រើនខាងនឹងឈ្នះហើយ អានឹងន័យចឹងចាញ់កម្លាំងនយោបាយ កម្លាំងយោធាអានឹងវាទាំងពីរដើរទន្ទឹមគ្នាបានទៅរួច ។ ហើយមួយទៀតគឺកម្លាំងប្រជាពលរដ្ឋដែលចិញ្ចឹម កម្លាំងសេដ្ឋកិច្ចគេ បើថាចិញ្ចឹមផ្គត់ផ្គង់ពីបរទេស ខាងនេះឲ្យខាងនោះឲ្យមិនបាច់រំពឹងថា ងាយរស់ទេ ឧទាហរណ៍ថាយើង គេជៀលថាពឹងចិន អានោះគេជៀលថាពឹងយួន ទៅយកសេដ្ឋកិច្ចពីយួនពីចិនមកស៊ីបាន ។ សូម្បីតែគ្រាប់កាំភ្លើងនឹងក៏ចឹងដែរ ចឹងបានខូះថារដ្ឋប្រហារហើយយើងពឹងចិន ពឹងអីមក អត់ទេខ្ញុំ ។ បើនិយាយគេមិនដឹងទេ បើខ្ញុំៗថាខ្ញុំពាក្យមួយឯកភាជម្ចាស់ការ ធ្វើយ៉ាងណាឲ្យបានហូប បានចុក បានគ្រប់សម្ភារៈប្រើប្រាស់ ធ្វើម៉េចអានឹងល្បិចរៀងខ្លួន ។ ចឹងតឹងតែងណាស់ក្មួយ មិនងាយស្លាប់រស់ ឱនណាស់មនុស្សរាប់រយរាប់ពាន់ ហើយគ្រាប់កាំភ្លើងរាប់រយរាប់ពាន់ គ្រាប់បែកទម្លាក់រាប់សិបម៉ាថ្ងៃៗរាប់សិប ។

ដានី : លោកតាអត់ទាន់មានប្រសាសន៍ថា ទាក់ទងរឿងគ្រាប់បែក ចុះពេលដែលលោកតានិយាយទៅតាំងពីយើងចេញរដ្ឋប្រហារឆ្នាំ៧០មក ។ ពេលដែលយើងទៅតស៊ូតាមអីនឹងមានគ្រាប់អីទម្លាក់អី?

សាន : ទម្លាក់៧៣ ។

ដានី : ៧៣?

សាន : បាទ! ទម្លាក់៧៣ និយាយទៅគេទម្លាក់ជាប់ អានឹងគ្រប់កន្លែងឲ្យគេដឹងត្រង់នឹង គេទម្លាក់ត្រង់នឹងព្រៃ ភូមិ ។ ដូចខ្ញុំនៅខាងកើតភ្នំនឹង នៅខាងត្បូងភ្នំជីសូរ ហៅភូមិស្រែអន្ទិតនឹង ៦គ្រឿងហើរអស់ផ្ទះ ។

ដានី : ហើរចំផ្ទះម៉ង?

សាន : បាទ! ទៅចុះភូមិ មានអ្នករាយការណ៍នៅនឹងមួយ រាយការណ៍វាឡើងដើម កុំអីក៏យើងអត់ដឹងដែរ យើងតាមដានគេអូ វាថាវានៅលើដើមត្នោតខាងកើតភូមិ អាយកការណ៍វានៅពីលើក្រវិល ។ អានេះវាសួរៗចេះឆ្លើយ ខ្ញុំតាមដានពុ ហើយវាដមិនទម្លាក់ចំ បើយើងមានអ្នករាយការណ៍នៅជិតនេះ ។ បើប្រជាពលរដ្ឋកាលនឹងដឹងថាគេទម្លាក់គ្រាប់បែកចឹងគាត់ចេញទៅនៅតាមវាលស្រែ ទៅតាមដំបូក តាមព្រៃអស់ គិតទៅវាទម្លាក់នៅគ្រប់ ។

ដានី : លោកតាមានគិតថាការទម្លាក់គ្រាប់បែកនឹង វាធ្វើឲ្យខាងយើង ដូចថាខាងដែលយើងប្រឆាំងជាមួយអ្នកដែលទម្លាក់គ្រាប់បែកនឹង វាងាយស្រួលកាន់តែងាយស្រួលៗចុះទៅអប់រំ?

សាន ៖ បាទ! ហ្នឹងប្រហែលជានៅត្រង់នឹង បើខ្ញុំនេះវាអត់ចាំ នៅត្រង់នេះតិចនៅខាងនោះតិច ។ ដូចនៅភូមិអាស្ទីគេខាងកើតស្រង់នឹងក្មេចឈ្មោះភូមិហើយ ស្វាយទាប ភូមិឫស្សីស្រុក ពាភូមិ អានឹងក៏ពាភូមិខ្ទេចហើយ ។

ដានី ៖ នៅខាងណា?

សាន ៖ នៅស្រង់ ស្រុកស្រង់ ។

ដានី ៖ ស្រង់ ខាងភ្នំស្រុល?

សាន ៖ បាទ! ភ្នំស្រង់ខាងលិចត្រាំខ្នារ ស្វាយទាប ស្រែអីទេ ឫស្សីស្រុក ពាភូមិនឹងខ្ទេច អានឹងខ្ញុំនៅម៉ាវរៈសេនាធំ ទម្លាក់ខ្ទេចទាំងអស់ ប្រជាពលរដ្ឋនៅនឹង គ្រាប់បែកហើយនឹងពួកទ័ពយើងបញ្ហាបាន ដឹងថាគេទម្លាក់ហើយ រត់ម៉ង រត់ចេញទាំងអស់ ព្រោះប្រជាពលរដ្ឋលែងនៅក្នុងភូមិហើយ ពេលនោះ ពី៧២ ៧៣អត់នៅទេ ។

ដានី ៖ ប៉ុន្តែកាលទម្លាក់គ្រាប់បែកនឹង វាមានមនុស្សច្រើនដែរ?

សាន ៖ ស្លាប់ៗស្វាយទាប ស្លាប់អស់១៨នាក់ ។

ដានី ៖ ស្លាប់អស់១៨នាក់?

សាន ៖ បាទ! ពួកម៉ាស្រែអន្ទិតនឹង អត់ទេ ស្លាប់តែទ័ពខ្ញុំមួយទេ វាគោងលើផ្ទះ វាអត់សុខចិត្តលោតរត់នឹងគេ វាអត់ហ៊ាន វាក្មេងថ្មី អាចាស់ៗវារត់អស់ ។

ដានី ៖ នៅស្រែអន្ទិត នៅខាងភ្នំជីសូរវិញ?

សាន ៖ បាទ! ខាងត្បូងភ្នំជីសូរ ។

ដានី ៖ តែទម្លាក់ម៉ាឆ្នាំ៧៣នឹងទេ ម៉ាជំនៀរនឹង?

សាន ៖ បាទ! ៧៣ ៧៤ ។

ដានី ៖ ៧៣ ៧៤?

សាន ៖ ចុង៧៣ មកដើម៧៤ មក៧៥ ពីរឆ្នាំខ្លាំង អ្នកនៅគ្រប់កន្លែងមិនបានចាំអស់ ។

ដានី ៖ ប៉ុន្តែពេលដែលកងទ័ពយើងវៃចូលមក ដូចជាគណៈបញ្ជា ដូចជាលោកតាអីយើងនៅជិតៗកងទ័ពនឹងដែរ ឬក៏នៅឆ្ងាយ ។

សាន ៖ អានឹងនិយាយតាយុទ្ធសាស្ត្រ បើកាលណាជាមេនៅណា នោះកូនមិនខ្លាំងទេ បើមេនៅជាប់ ។

ដានី ៖ ទាល់តែនៅជាប់?

សាន ៖ ទឹងសមរភូមិ ជាប់ទឹងកម្ចាំង ជួយវិធី ជួយវិធានការណ៍អីក្លាមៗបានខ្លាំង ឧទាហរណ៍ថា យើងមកពីថ្ងៃចឹង យើងអត់ហ៊ានមកទេ។ ទាល់តែយប់ឡើងយើងមកមើលទៅ ដកអានេះ ថែមអានោះ ដកអានោះថែមអានេះ ដូចយើងលេងវែកចឹង ដល់ចែកទ័ព។

ដានី ៖ ទាល់យើងមកជាប់កងទ័ព បានយើង។

សាន ៖ អន់ណាស់ដល់ត្រឹមអនុសេនាធំ ពី២៥នាក់ ៣០នាក់ សមរភូមិវាអត់អស់ទេ ដូរគ្នា។

ដានី ៖ ចឹងលោកតាទៅជាប់ចឹងមក ជាមួយកងទ័ព ឬក៏មិនបាច់?

សាន ៖ មិនជាប់រាល់ថ្ងៃទេ គ្រាន់ថាពេលណាដែលយើងត្រូវដូរ យើងទៅមើល វិធានការណ៍ណា ដែលយើងត្រូវដូរ យើងទៅមើល។

ដានី ៖ ចុះដូចតាសឿង គាត់មកជាប់ដែរអត់?

សាន ៖ អត់ទេ។

ដានី ៖ តាសឿងអត់?

សាន ៖ គាត់នៅឆ្ងាយៗ២-៣-៤-៥គីឡូ តាមភូមិ។

ដានី ៖ តែលោកតាមកជាប់ជាង?

សាន ៖ បាទ!

ដានី ៖ ចុះដល់ពេលយើងបែកភ្នំពេញឆ្នាំ៧៥ហើយ ពេលដែលយើងជ័យជំនះហើយយ៉ាងម៉េច ទៅ?

សាន ៖ ជ័យជំនះហើយ ខ្ញុំមកនៅលង្វែក ចែកគ្នា ខ្ញុំមកនៅលង្វែកជាមួយតាសឿង។

ដានី ៖ ជាមួយតាសឿងដែរ?

សាន ៖ បាទ!

ដានី ៖ កងពលមកទាំងអស់ ម៉ាកងពលលោកតា?

សាន ៖ កងពលនៅរាយ អត់ទេ ដាក់តាមឃុំអស់ហើយ ចែកទៅតាមឃុំ៧៥។ ដល់៧៦ផ្លាស់ទៅ នៅកោះ។

ដានី ៖ ទៅនៅណា?

សាន ៖ នៅកោះៗកុង។

ដានី ៖ ទៅនៅខាងកោះកុងវិញ?

សាន ៖ បាទ! នៅនោះកោះកុង កងទ័ពវានៅកងតំបន់វានៅនឹង តែអាកងភូមិភាគនឹងត្រូវទៅកោះ កុង២វរៈសេនាធំ។ ហើយដល់ខ្ញុំនៅតាមមន្ទីរតាមអីនៅលង្វែក។

ដានី ៖ តែមន្ទីរកងពលនៅណា នៅលង្វែក?

សាន ៖ នៅលង្វែក ។

ដានី ៖ ចឹងលោកតានៅលង្វែក?

សាន ៖ បាទ!

ដានី ៖ អានឹងយើងនៅជាកងពលរបស់ភូមិភាគបស្ចិម ឬក៏យ៉ាងម៉េច?

សាន ៖ ភូមិភាគបស្ចិម ។

ដានី ៖ នៅកងពលភូមិភាគបស្ចិមដដែល?

សាន ៖ បាទ!

ដានី ៖ ចឹងលោកតា ហើយតាសឿង គាត់នៅក្នុងមន្ទីរកងពលនឹង?

សាន ៖ បាទ!

ដានី ៖ ចឹងលោកតាមានប្រសាសន៍មិញថា២វរៈសេនាធំដែលយើងទៅកោះកុង អានឹងយើងអត់ទៅតាមទេ?

សាន ៖ បាទ! អត់ទេ ព្រោះផ្លូវវាមានហើយ ឡានវាមានហើយថ្ងៃណាទៅៗ ថ្ងៃណាអត់ទៅៗ ។

ដានី ៖ ទៅកោះកុងយើងទៅការពារអី ទៅធ្វើអី?

សាន ៖ បាទ! ទៅនៅចាំតាមព្រំដែន ។

ដានី ៖ ចាំព្រំដែន?

សាន ៖ បាទ!

ដានី ៖ ព្រំដែនគោក?

សាន ៖ បាទ! ព្រំដែនគោក ព្រំដែនទឹកគេកម្លាំងគេមានផ្សេង ។

ដានី ៖ ព្រំដែនទឹកមានកម្លាំងផ្សេងទៀត?

សាន ៖ បាទ! ព្រោះនៅដូចកងទ័ពយើងឥឡូវចឹង ឃើញទេ មានជើងគោក ហើយមានប៉ូលីសព្រំដែន ឃើញទេ វាមាន២ ។ ហើយប៉ូលីសមាន២ អាមួយប៉ូលីសស្រុកការពារនៅតាមឃុំ អាប៉ូលីសព្រំដែន ខ្ញុំមិនយល់ថាប៉ូលីសស្អីទេ គ្រាន់ឮចឹង ខ្ញុំមិនបានរៀនសូត្រ មិនបានដឹង គ្រាន់តែឮៗ ។ ចឹងប៉ូលីសព្រំដែនវាមាននៅតាំងពីយើងនៅរហូតដល់អន្លង់វែងដល់អីនឹង អានឹងមានប៉ូលីសព្រំដែន ។

ដានី ៖ ចឹងកងពលលោកតាអត់មានដូរឈ្មោះដូរអីទៀតទេ?

សាន ៖ អត់ទេ ។

ដានី ៖ នៅកងពលទី១ដដែល?

សាន ៖ បាទ!

ដានី ៖ ពីព្រោះបានជាចឹង ពីព្រោះកងពលភាគច្រើនពេលដែលបែកពីភ្នំពេញឆ្នាំ៧៥មក យើងដូរឈ្មោះទៅជាកងពលរបស់មជ្ឈឹមរបស់សេនាធិការមក?

សាន ៖ សេនាធិការ ពួករឿន ពួកអីនោះ ពួកសេនាធិការ ។ ពួកភូមិភាគពិសេស ពួកទៅសេនាធិការ ។

ដានី ៖ ឡើងទៅសេនាធិការ?

សាន ៖ បាទ!

ដានី ៖ កងពលរបស់គាត់ ត្រូវទៅខាងរតនគិរី ទៅខាងអីនឹង?

សាន ៖ អត់មានទៅទេ ។

ដានី ៖ របស់តាសារឿន០៥?

សាន ៖ បាទ! នឹងខាងសេនាធិការ ពួកខាង ។

ដានី ៖ ខាងសេនាធិការ ដល់ពេលដែលឈ្នះឆ្នាំ៧៥ហើយ កងពលរបស់គាត់ត្រូវគេដូរឈ្មោះទៅជា៨០១ ។

សាន ៖ ៨០១ ។

ដានី ៖ ៨០១ ត្រូវមានភារកិច្ចទៅការពារព្រំដែននៅខាងភាគឥសាន ទៅខាងរតនគិរី ។ ហើយកងពលមួយទៀត មកពីខាងភូមិភាគខត្តរ ទៅខាងកងពលទី២ ទី៣នឹង ពេលមកឈ្នះ៧៥ក៏ឡើងទៅជាសេនាធិការដែរ ។ សេនាធិការទៅខាងកងពល៩២០ របស់តាឈិន របស់តាសយអីនឹង ។

សាន ៖ ខ្ញុំអត់សូវស្គាល់ទេ ។

ដានី ៖ បាទ! អានឹងគាត់ទៅខាងមណ្ឌលគិរី ។ ដូចកងពល៧០៣អី មិនឡើងពីកងពលសេនាធិការដែរ?

សាន ៖ បាទ! សេនាធិការទាំងអស់ ឲ្យតែភូមិភាគពិសេសទៅសេនាធិការទាំងអស់ ។

ដានី ៖ ភូមិភាគពិសេស ហើយភូមិភាគនិរតីម៉ាចំនួនដែរ?

សាន ៖ បាទ!

ដានី ៖ ដូចច័ន្ទចក្រីអីក្រែងឡើងទៅសេនាធិការដែរ?

សាន ៖ ច័ន្ទចក្រី គាត់នៅខាងភូមិភាគខត្តរ ។

ដានី ៖ ភូមិភាគបូព៌ា?

សាន ៖ អូ! បូព៌ា ។

ដានី ៖ គាត់ឡើងមក?

សាន ៖ សេនាធិការ ។

ដានី ៖ សេនាធិការ ។

សាន ៖ ពួកខ្ញុំនេះទៅសេនាធិការទៅម៉ារៀបចំទៅមន្ទីរគេ ដូចម៉េតដូចអីគាត់ទៅកាប៉ាល់ហោះ ។

ដានី ៖ គាត់ទៅខាងកាប៉ាល់ហោះ?

សាន ៖ បាទ!

ដានី ៖ អ៊ំស្គាល់តាម៉េតច្បាស់ដែរ?

សាន ៖ នៅស្រុកជាមួយគ្នា ។

ដានី ៖ នៅស្រុកជាមួយគ្នា ។ បាទ! ចេញតស៊ូ កាលនោះចេញជាមួយគ្នាដែរ ឬក៏អត់ទេ?

សាន ៖ ចេញជាមួយគ្នា ។

ដានី ៖ ចេញអាពេលដែលយើង?

សាន ៖ បាទ! ទៅជាមួយគ្នាទាំងអស់ ។

ដានី ៖ ទៅយុទ្ធអីជាមួយគ្នា?

សាន ៖ បាទ!

ដានី ៖ អាពេលដែលយើងតាម លោកតាថាមានប្រសាសន៍ថា៦៨នាក់ដែលយើងចេញ ក្នុងចំណោមនឹងមានតាម៉េតមួយដែរ?

សាន ៖ បាទ!

ដានី ៖ កាលនឹងដល់ពេលយើងចេញតស៊ូ ចេញតាមពីម៉ាកន្លែងទៅម៉ាកន្លែងនឹង ទៅជាប់ជាមួយលោកតាដែរ តាម៉េត?

សាន ៖ បែកគ្នា ។

ដានី ៖ បែកគ្នា?

សាន ៖ ដល់ពេលចុះមកភូមិវិញ គេចែកគ្នា បើយើងវាតិចចឹងទៅរកកម្លាំងរៀងខ្លួន ទៅរក៣-៤នាក់ចឹងទៅ ចែកអាកម្លាំងវាច្រើន ។ យើងទៅពីពេលនឹង វាទៅជាធ្វើមេទាំងអស់ អ្នកណាដែលមានសមត្ថភាពច្រើនជាងគេ ទៅជាមេចឹងទៅ អ្នកណាអត់ទេ ធ្វើកូន២-៣នាក់យូរទៅវាទៅជាមេទាំងអស់ ។

ដានី ៖ ចឹងកងពលលោកតានៅមន្ទីរកងពលនៅលង្វែករហូតដល់ពេលណា?

សាន ៖ ពេលយួនវាយបណ្តោយ ។

ដានី ៖ ចឹងម៉ា២វរសេនាធំ ទៅការពារព្រំដែននៅកោះកុង ហើយម៉ាវរៈសេនាធំទៀតនៅណា?

សាន ៖ នៅតាមបន្ទាយ ដូរគ្នាចុះឡើង ។

ដានី ៖ ចុះលោកតាធ្វើការយ៉ាងម៉េចខ្លះទៅ បើយើងនៅបន្ទាយចឹង យើងដូចថាពេលនឹង?

សាន ៖ អត់មានធ្វើអីទេ ដឹកនាំកងទ័ពធ្វើស្រែ យកកម្លាំងធ្វើស្រែធ្វើអី ធ្វើស្រែបន្ទាប់បន្សំ មិនមែនធ្វើទាំងអស់ទេ ។ គ្រាន់ថាយើងមិនធ្វើខ្លះវាអត់អីជាគំរូដល់ពលរដ្ឋ ដល់ចឹងយើងធ្វើចំណែកណា ៗ ។ ចឹងវានៅអត់នៅទំនេរទេ កាលនៅនោះ មិនមានទំនេរដូចទាហានយើងឥឡូវទេ ទាហានយើងឥឡូវមានទំនេរអង្គុយដឹកស៊ី អង្គុយលេងបៀរ ជំនាន់នោះអត់មានទេ ។

ដានី ៖ ធ្វើតែស្រែធ្វើអី ឲ្យទំនេរ?

សាន ៖ បាទ! អត់ទេ អ្នកនៅនឹងធ្វើស្រែ ដាំដូងដាំអី នៅកន្លែងណាធ្វើចំការ ធ្វើស្រែនៅកន្លែងនឹងដាំនឹង ព្រោះវាអស់ការងារច្បាំងហើយ ។ ដល់ពេលយួនវៃមកនៅសល់តែដី ដាំ ។

ដានី ៖ ចុះកាលនោះមន្ទីរភូមិភាគបស្ចឹមនៅណាទៅ?

សាន ៖ នៅកំពង់ស្ពឺ ។

ដានី ៖ នៅកំពង់ស្ពឺម៉ង?

សាន ៖ បាទ! ពេលដែលឈ្នះហើយ ។

ដានី ៖ បាទ! ពេលឈ្នះហើយ ពេលឈ្នះហើយយើងនៅកំពង់ស្ពឺ នៅច្បារមន?

សាន ៖ បាទ!

ដានី ៖ ភូមិភាគបស្ចឹមមានប៉ុន្មានខេត្ត កំពង់ស្ពឺ?

សាន ៖ អត់ទេ កំពង់ស្ពឺ កំពង់ឆ្នាំង កោះកុងគេផ្សេង តំបន់គេផ្សេងទៀត ។

ដានី ៖ តំបន់កោះកុងគេផ្សេងទៀត?

សាន ៖ បាទ!

ដានី ៖ ប៉ុន្តែគេដកឲ្យខាងកង?

សាន ៖ កងទ័ពអត់ទេ កងទ័ព ភូមិភាគវាគ្រប់គ្រងតែកោះកុង កំពង់ស្ពឺ កំពង់ឆ្នាំង ទាំងនិរតីក៏ចឹងដែរ ព្រោះអានឹងវាកងទ័ពរបស់ភូមិភាគ ។ ចឹងភូមិភាគណាគេត្រូវការគេទៅពេលនឹង អត់មានទេ ។ គេចែកគ្នាគ្រប់គ្រងតាមមុខរៀង ៗ ខ្លួន ។

ដានី ៖ ចុះតាសឿង គាត់អ្នកស្រុកកំណើតនៅណាដែរ?

សាន ៖ តាសឿង ស្រុកកំណើតគាត់នៅម្តុំត្រាំកក់ ម្តុំនេះដែរ មិនដឹងនៅត្រង់ណា ខ្ញុំវាមិនច្បាស់ ។

ដានី ៖ ខាងត្រាំកក់ ខាងតាកែវ?

សាន ៖ បាទ! ខាងតាកែវ ។

ដានី ៖ ចឹងលោកតាស្គាល់ តាប៊ិតអីច្បាស់ដែរ?

សាន ៖ បាទ! ព្រោះស្គាល់ជាមួយគ្នាតាំងពីនៅព្រៃ។

ដានី ៖ នៅព្រៃពេលតស៊ូអី?

សាន ៖ បាទ!

ដានី ៖ តាប៉ិត កងចាប តាសែនឹង ក៏ស្គាល់ដែរ?

សាន ៖ សែ ស្គាល់។

ដានី ៖ គាត់តស៊ូពីអង្កាល់មកដែរ?

សាន ៖ តាសែនេះគាត់ សុទ្ធតែពួកនិស្សិតមកពីនេះ មកពីនោះខ្ញុំមិនស្គាល់ ដឹងថាគាត់ចេញពីក្រុមណា។ តែដល់តែ៧១ ៧២នឹង បានឃើញ។

ដានី ៖ ៧១ ៧២?

សាន ៖ ហ្នឹង៧១ តាសែ នៅដូចជាពួកនៅតំបន់នៅអី អានឹងគេរត់បែកបាក់មក តិរះវិដ្ឋាបានគេនៅខាងនេះ ខាងយោធាគេថា អ្នកណាដែលសកម្មខាងយោធា គេប្រគល់ឲ្យខាងយោធា។ អ្នកណាមានស្មារតីខាងយោធា ប្រយុទ្ធ អ្នកដែលអត់ស្មារតីយោធាប្រយុទ្ធ នៅ។

ដានី ៖ ចឹងកងពលយើងនៅខាងភូមិភាគបស្ចិមនឹង យើងធ្វើការតែក្នុងក្របខ័ណ្ឌភូមិភាគទេ យើងអត់មានធ្វើការជាមួយសេនាធិការដែរ អត់ទេ?

សាន ៖ អត់ទេ ជាមួយភូមិ ជាមួយឃុំអីអត់ទេ។

ដានី ៖ អត់ទេ?

សាន ៖ បាទ! ព្រោះយោធាគ្រប់គ្រងតែយោធា។

ដានី ៖ គ្រប់គ្រងតែយោធា?

សាន ៖ បាទ! ចឹងការលំបាក ការស្រួលអីអត់ដឹង។

ដានី ៖ ប៉ុន្តែឧបមាថាយើងត្រូវរៃត្រូវអី យើងទទួលបញ្ជាពីខាងសេនាធិការ ឬក៏ពីខាងភូមិភាគ?

សាន ៖ ភូមិភាគ។

ដានី ៖ ចុះពេលដែលយើងមានសង្គ្រាមជាមួយយួនអីនឹង ដូចកងពលលោកតាអីមានបានទៅសមរភូមិ បានទៅរៃអីនៅតាមទល់ដែនដែរ?

សាន ៖ អត់ទេ កាលនោះខាងកើត នៅខាងកើត។

ដានី ៖ ខាងកើត ប៉ុន្តែគេច្រើនដែរជួយអន្តរគមន៍ គេដកពីកងពលសេនាធិការទៅ?

សាន ៖ បាទ! ដក។ ខ្ញុំ៨កងពល។ ពេលវៃយួននេះ ខ្ញុំទៅនៅ ចាស់ហើយគេឲ្យមកតំបន់។

ដានី ៖ លោកតាមកខាងតំបន់វិញ?

សាន ៖ បាទ!

ដានី ៖ មកគ្រប់គ្រងតំបន់?

សាន ៖ បាទ!

ដានី ៖ លោកតានៅតំបន់ណា?

សាន ៖ នៅតំបន់កំពង់ស្ពឺ ។

ដានី ៖ តំបន់លេខប៉ុន្មានអានឹង?

សាន ៖ អឺ! ភ្លេចលេខ ។

ដានី ៖ ពីព្រោះភូមិភាគបស្ចិមមានប៉ុន្មានតំបន់?

សាន ៖ មានតំបន់កោះកុង ។

ដានី ៖ តំបន់កោះកុង?

សាន ៖ អឺ! តំបន់កំពង់ឆ្នាំងនេះ ។

ដានី ៖ តំបន់កំពង់ឆ្នាំង ហើយនឹងតំបន់កំពង់ស្ពឺ?

សាន ៖ បាទ! កំពង់ស្ពឺ មាន៣ ។

ដានី ៖ មាន៣ ចឹងលោកតាផ្លាស់ពីកងទ័ពមក?

សាន ៖ ចេញពីកងទ័ព ពីខែៗប៉ុន្មាន ខែ៧ ។

ដានី ៖ ខែ៧?

សាន ៖ បាទ!

ដានី ៖ ខែ៧ ៧០ប៉ុន្មាន?

សាន ៖ ៧៥ ។

ដានី ៖ ចឹងខែ៧ ឆ្នាំ៧៥ លោកតាមក?

សាន ៖ រៀបចំកងពលអីៗដាក់ទ័ពអីហើយនឹង យើងចាស់ គេដក ទៅនៅតំបន់ ព្រោះខាងតំបន់នឹង គេដកខាងៗណាទេ កាលនឹងភ្លេចឈ្មោះ ដកអ្នកណាដកចាស់ៗនឹង ឲ្យទៅទីប្រឹក្សារបស់ខាងក្រុមអស់ទៅ ។ គេឲ្យខ្ញុំទៅនៅតំបន់ ពីមុនបងវ៉ន....ក្រោយមឡើងវ៉នទៅនោះទៅ ។

ដានី ៖ វ៉ន គាត់ទៅណា?

សាន ៖ កាលនឹងដូរ វ៉ន ទៅកោះកុង បានឲ្យខ្ញុំមកនៅ ។

ដានី ៖ មកនៅតំបន់?

សាន ៖ តំបន់កំពង់ស្ពឺនឹង ។

ដានី ៖ តំបន់៣០ប៉ុន្មាន កាលនឹងមានលេខគេ?

សាន ៖ លេខច្រើន មិនដឹង៣០ប៉ុន្មានទេ ។

ដានី ៖ ចុះតាប៉ាល់គាត់គណៈភូមិភាគ ប៉ុន្តែគាត់ទទួលតំបន់មួយដែរ?

សាន ៖ បាទ! គាត់គ្រាន់តែជួយ ភូមិភាគ តែគាត់នៅក្នុងតំបន់នឹងដែរ គាត់ជាសមាជិកតំបន់វិញ ហើយគាត់នៅនឹង គាត់ជាសមាជិតតំបន់ ។

ដានី ៖ តំបន់?

សាន ៖ បាទ! សម្រាប់ជួយដំណើរការស្អីៗ ។

ដានី ៖ លោកតាជាលេខាតំបន់?

សាន ៖ អត់លេខាទេ ។

ដានី ៖ បាទ?

សាន ៖ មិនមែនលេខាទេ ។

ដានី ៖ លេខាពីណាគេ?

សាន ៖ អឺ! កំពុងរកនឹកភ្លេចឈ្មោះ ។ ខ្ញុំគ្រាន់ទៅជំនួយការតំបន់ យើងវាចាស់ធ្វើទ័ពលែងកើតទៅ នៅជំនួយការងារគេ ។

ដានី ៖ តំបន់នឹង យើងនៅជិតភូមិភាគបស្ចឹមដែរ ជិតមន្ទីរភូមិភាគបស្ចឹម?

សាន ៖ បាទ! ឥឡូវគេហៅទំនប់ អឺ!វាភ្លេច ទៅជាអូរក្រាំងវិល នៅក្រាំងចេកនឹង ។

ដានី ៖ អូ! ទំនប់ក្រាំងចេកនឹង?

សាន ៖ បាទ!

ដានី ៖ ទំនប់ក្រាំងចេកវាមកខាងឧត្តុងខាងនេះវិញ?

សាន ៖ បាទ! ទំនប់ក្រាំងចេក ។

ដានី ៖ នឹងតំបន់នៅកន្លែងម៉ុនឹងវិញ?

សាន ៖ អឺ! នៅខាងលិចវត្តក្រាំងចេក នៅភូមិនឹង ។

ដានី ៖ ចុះពេលនឹងលោកតាដូចថា គ្រួសារលោកតានៅខាងនេះនឹងលោកតា?

សាន ៖ នៅតាមភូមិរបស់ខ្លួនដែរ ។

ដានី ៖ នៅភូមិ តែយើងអត់មក យកមកនៅជាមួយពេលយើងជ័យជំនះហើយ?

សាន ៖ អត់ៗទេ ។

ដានី ៖ ពេលយើងជ័យជំនះហើយ?

សាន ៖ អត់ទេ ។

ដានី ៖ អត់ទេនោះ ម៉េចចឹងលោកតា?

សាន ៖ នៅលង្វែក បាទខ្ញុំយកមកលង្វែក បាទខ្ញុំរៀបចំឲ្យគាត់ទទួលបន្ទុកខាងតម្បាញ ខាងកាត់ដេរខាងអីទៅ គាត់នៅជាប់ការងារគាត់នឹង យើងទៅៗ ។

ដានី ៖ គាត់មកនៅខាងលង្វែកវិញ?

សាន ៖ បាទ! នៅលង្វែកវិញ ប៉ុននៅខត្តកណ្ដាលរៀនកាត់ដេរ ។

ដានី ៖ ដល់ពេលលោកតាមកនៅ ដល់ពេលយើងមកនៅតំបន់អី ក៏មកនៅម្នាក់ឯងដែរ អត់ៗមានគ្រួសារមកជួបមុខ?

សាន ៖ បាទ!

ដានី ៖ ចុះកាលនឹងយើងយ៉ាងម៉េច បានយើងដូចថាយើងប្ដីប្រពន្ធកូនអី យើងអត់បានមកនៅជុំគ្នា?

សាន ៖ អានឹងវាអត់មានភូមិដែលយើងនៅស្រួលពិតប្រាកដ នឹងបើតាមការមើលទៅ ហើយយើងអត់ទាន់ដូចកំណត់ថាយើងនៅភូមិណា នៅកន្លែងណាចឹង ទម្លាប់អាភាត់អាភាយចឹងមក ចេះនៅអាភាត់អាភាយចឹងទៅ ។

ដានី ៖ ចុះដូចថាលោកតាមានប្រពន្ធ មានកូនអីចឹង កាលនោះយើងអត់នៅជុំគ្នា យើងបែកគ្នាចឹងដូចថាយើងនៅ?

សាន ៖ ចុះគ្រាន់តែទទួលប្អូន នៅមួយភ្លែតៗ នៅឯងនឹងមានការងារធ្វើ បានទៅធ្វើ អត់ទៅមកនៅផ្ទះវិញ នៅកន្លែង ។

ដានី ៖ នៅយើងនៅជួបជុំគ្នាដែរ?

សាន ៖ បាទ!

ដានី ៖ ចុះតាជូ ជេត តាស៊ីនឹង គាត់នៅដូចថានៅច្បារមននឹង ដល់ពេល?

សាន ៖ អត់ទេ ។ ដូច្នេះហើយ គាត់នៅផ្លូវបំបែកនេះតើ ។

ដានី ៖ នៅណា ផ្លូវបំបែកណា?

សាន ៖ ផ្លូវបំបែកកំពង់លួង ។

ដានី ៖ នៅកន្លែងកំពង់លួង?

សាន ៖ ធ្លាប់ចុះទៅកំពង់លួង ផ្លូវកំពង់លួង ផ្លូវទៅភ្នំពេញ ។

ដានី ៖ ហួសមកខត្តកណ្ដាល?

សាន ៖ គាត់នៅនឹង កន្លែងគាត់ ។

ដានី ៖ ជិតវត្តព្រែកប្រាង្គមួយនឹង?

សាន ៖ បាទ! ជិតវត្ត ម្ដុំៗត្រង់នឹង ។

ដានី ៖ ចឹងដល់ពេលយើងដូចថាក្នុងនេះចឹង ពេលដែលយើងមកជួបជុំគ្នាប្រជុំអី ខស្សាហ៍ប្រជុំដែរ ឬក៏មិនសូវទេ?

សាន ៖ ប្រជុំដែរប្អូន ។

ដានី ៖ ប្រជុំ?

សាន ៖ បាទ! ប្រជុំតាមខែ ។

ដានី ៖ តាមខែ ម៉ាខែប្រជុំម្តង?

សាន ៖ បាទ!

ដានី ៖ ម៉ាខែម្តង ឬម៉ាខែ២ដង ៣ដង?

សាន ៖ ម៉ាដងទេ ។

ដានី ៖ ម៉ាខែម្តង?

សាន ៖ បាទ!

ដានី ៖ ពេលប្រជុំៗភាគច្រើនប្រជុំរឿងស្អីទៅ?

សាន ៖ ប្រជុំពីការបង្កបង្កើនផល ពេល...លើកទំនប់ ធ្វើប្រឡាយអីដើម្បីដោះស្រាយបញ្ហាទឹក ។

ដានី ៖ ដោះស្រាយបញ្ហា?

សាន ៖ បាទ! នេះគម្រោង វាមានខ្លះធ្វើខុស ខ្លះធ្វើត្រូវចឹងហើយ វាមិនត្រូវទាំងអស់ណា យើងអត់បានត្រួតពិនិត្យច្បាស់លាស់ គឺខុសហើយ ។ ពេលដែលឈ្នះហើយនឹង ពេលដែល៧៥ ៧៦ នឹងមិនទាន់រស់ប៉ុន្មានផង អាអ្នកធ្វើខុសច្រើនណាស់ ។ ខទាហរណ៍ ។

ដានី ៖ ខុសយ៉ាងម៉េចលោកតា?

សាន ៖ ខុស គេមានអ្នក២ចឹង ដែលខ្ញុំដឹង វាមានអ្នកជាមួយខ្លួន មានអ្នកជាមួយដឹកនាំ ។ ខ្ញុំជាប់គុក គេដកយកទៅវៃចោលម្តង ប៉ុន្តែវា ។

ដានី ៖ ឆ្នាំណា គេដក?

សាន ៖ ៧៥ឈ្នះហើយ តាស៊ីមិនបបួលទៅធ្វើសង្គ្រាមម្តងទៀត ។

ដានី ៖ បាទ!

សាន ៖ ខ្ញុំថាអត់ទេ បងស៊ីនឹងគាត់ជំនិត ខ្ញុំនឹងហើយជាអ្នកជំនិតជាមួយគាត់ ព្រោះទៅណាមកណាទៅជីវរមាល មកឱរ៉ាល់អីតែ៣នាក់ក៏មក ។ ព្រោះខ្ញុំអ្នកដើងជំនិត ដើង ហើយដល់ចប់សង្គ្រាម គាត់ហៅខ្ញុំទៅសួរ ខ្ញុំថា«ខ្ញុំមិនធ្វើជាមួយបងឯងទៀតទេ» នឹងហៅទៅសួរនៅកំពង់លួង ។

ដានី ៖ គាត់ហៅទៅសួរកំពង់លួង?

សាន ៖ ហ្នឹងហើយ ខ្ញុំថាអត់ធ្វើ ។

ដានី ៖ តាស៊ីគាត់ហៅ?

សាន ៖ ដល់ខ្លាចខ្ញុំដឹងរឿង គេដកខ្ញុំចេញពីទ័ព ។ នៅតាម៉ុកដឹង បានហៅឲ្យធ្វើគណៈតំបន់វិញ ដកជិតម៉ាឆ្នាំដករលាប្អៀរ ។

ដានី ៖ ចំមើលលោកតាដំបូងពីឆ្នាំ៧៥នឹង ពេលដែលលោកតាប្រកែកជាមួយតាស៊ីចឹងទៅ តាស៊ីគាត់ដកលោកតា?

សាន ៖ បាទ! មិនប្រកែកទេ គាត់ហៅទៅសួរ មិនចឹងដូចក្មួយឯងនិងខ្ញុំចឹងជំនិតអីដឹងគ្នាទៅវិញទៅមកអស់ហើយ ។ ហើយគាត់ប្រកាសថាមិនទាន់ចប់សង្គ្រាម ហើយខ្ញុំថាអត់ចប់ម៉េច បើវាចប់ហើយ ។ អត់ចប់ទេ នៅផ្សេងជាមួយគ្នាទៀតអត់ ខ្ញុំថាអត់ធ្វើទេ ។

ដានី ៖ ដល់ពេលអត់ធ្វើចឹង គាត់?

សាន ៖ អត់ធ្វើ មិនគាត់ប្រកាសឡើងបាត់ហើយ មិនចឹងៗគាត់ដកខ្ញុំចេញពីទ័ពឲ្យនៅក្នុងទ័ពទៀតទេ ព្រោះគាត់ខ្លាចខ្ញុំ ។ ដកខ្ញុំមកដាក់បរិបូរ ។

ដានី ៖ ដាក់មកបរិបូរ?

សាន ៖ បាទ!

ដានី ៖ ធ្វើអីទៅនៅបរិបូរ?

សាន ៖ អត់ទេ ដាក់យកមកទុកនៅជាមួយសហករណ៍ជាមួយអីនឹង ។

ដានី ៖ ជាមួយសហករណ៍ មិនមែនជាគណៈស្រុកទេ?

សាន ៖ អត់ទេ គណៈស្រុកគេមាន ។

ដានី ៖ គណៈស្រុកគេមាន?

សាន ៖ បាទ!

ដានី ៖ ប៉ុន្តែយើងដកមកយើង ប៉ុន្តែក្នុងជួរនឹងដែរ គ្រាន់តែបញ្ឈរជើងយើងគ្នា គណៈស្រុក?

សាន ៖ គ្រាន់បញ្ឈរជើង គេដកបញ្ឈរជើង ។

ដានី ៖ ចុះតាសឿងកាលនោះ?

សាន ៖ តាសឿងនៅកងពលខាងនោះ ។

ដានី ៖ តាសឿងនៅកងពលដដែល?

សាន ៖ ហ្នឹងហើយ ។

ដានី ៖ ប៉ុន្តែគេដកតែលោកតាមួយទេ?

សាន ៖ បាទ! ដកមកបរិបូរ តាំងពីជិតម៉ាឆ្នាំ ។

ដានី ៖ ដកមកជិតម៉ាឆ្នាំ?

សាន ៖ បាទ! បានទៅទទួលតំបន់បានម៉ាឆ្នាំ យួនចូល ។

ដានី ៖ អូ! ដល់ពេលលោកតាដកមកបរិបូរបានម៉ាឆ្នាំនឹង ដល់ពេលក្រោយមកលោកតាដឹងថា តាស៊ីគាត់ក្បត់ គេចាប់គាត់នឹង?

សាន ៖ បាទៗ ។

ដានី ៖ គេចាប់គាត់ទៅ ចាប់នឹងឆ្នាំណា?

សាន ៖ ខ្ញុំអត់ច្បាស់ទេ ។

ដានី ៖ អត់ច្បាស់?

សាន ៖ បើគេដក អស់គិត អស់ដឹងអីហើយ ។

ដានី ៖ ដល់ពេលគេចាប់តាស៊ីនឹងមក ចាប់តាស៊ី តាម៉ុកទៅដល់បានគាត់ស្រាវជ្រាវរកលោកតា?

សាន ៖ រកបានទៅបរិបូរ ។

ដានី ៖ នៅបរិបូរ?

សាន ៖ បានហៅឲ្យមកនៅតំបន់ ។

ដានី ៖ បានហៅលោកតាឲ្យមកធ្វើគណៈតំបន់នៅកំពង់ស្ពឺនឹង?

សាន ៖ អឺ!

ដានី ៖ ប៉ុន្តែលោកតាអត់ចាំឈ្មោះតំបន់នឹង៣០ប៉ុន្មានទេ ព្រោះបើតាមខ្ញុំដឹងដូចនៅក្នុង?

សាន ៖ ៣៣ ។

ដានី ៖ តំបន់៣៣ ក្នុងគណៈតំបន់មានគ្នាប៉ុន្មាននាក់?

សាន ៖ ៤នាក់ ៥ ៦ ៧ នាក់ គេដកពីតាមឃុំមក មួយៗទៀត ។

ដានី ៖ តំបន់៣៣?

សាន ៖ អឺ!

ដានី ៖ បើលោកតា មានពីណាទៀត បើតាមលោកតាចាំ លោកតាម្នាក់?

សាន ៖ ប្រធាន បើឈ្មោះឥឡូវនៅនេះ ។

ដានី ៖ នៅណា?

សាន ៖ នៅប៉ៃលិន...ភ្លេច វ៉ានៅនឹង ដកវ៉ានទៅ គេយកខ្ញុំទៅដាក់ ឲ្យវ៉ានទៅ៣៧ទៅ ឲ្យខ្ញុំទៅនៅនឹង តំបន់ ។

ដានី ៖ លោកតាទទួលបន្ទុកអីទៅនៅតំបន់ ដូចថាយើង?

សាន ៖ ទទួលបន្ទុកខាងគ្រប់គ្រងសហករណ៍ អប់រំ ។

ដានី ៖ គណៈអប់រំ?

សាន ៖ បាទ!

ដានី ៖ គណៈអប់រំ យើងទទួលបន្ទុកគ្រប់គ្រងមកខាងស្រុក មកឃុំមកអី?

សាន ៖ បាទ!

ដានី ៖ គ្រប់គ្រងប្រជាជនអានឹង?

សាន ៖ បាទ!

ដានី ៖ គណៈគ្រប់គ្រង ហើយហី?

សាន ៖ អានឹងចែកតិចៗម្នាក់ទេ ដូច៥នាក់ចឹង នេះទៅឃុំនេះ នេះទៅស្រុកនេះ នេះទៅស្រុកនោះ គេអត់មានទទួលបន្ទុកដោយឡែកដូចយោធាទេ ។

ដានី ៖ ចុះបន្ទាប់ពីតាស៊ី គេចាប់តាស៊ីទៅ ពីណាគេឡើងគណៈតំបន់បស្ចឹម អូ!គណៈភូមិភាគបស្ចឹម?

សាន ៖ អ៊ំប៉ាល់ ។

ដានី ៖ តាប៉ាល់?

សាន ៖ អឺ!

ដានី ៖ តាប៉ាល់ឡើងជំនួសតាស៊ី?

សាន ៖ បាទ!

ដានី ៖ ចុះតាប៉ាល់សព្វថ្ងៃគាត់នៅណា?

សាន ៖ ស្លាប់អស់ហើយ ។

ដានី ៖ គាត់ស្លាប់ពីអន្លុង?

សាន ៖ ហ៊ើ! មិនដឹងស្លាប់ពេលឆ្នាំប៉ុន្មាន ខ្ញុំអត់ចាំ ស្លាប់អស់នៅសល់តិចដែរ ។

ដានី ៖ ចឹងលោកតា ហើយនឹងតាម៉ុក លោកតាស្គាល់តាម៉ុកច្បាស់ដែរ បានជាពេលដែលគេចាប់?

សាន ៖ ស្គាល់ ព្រោះខ្ញុំតាម៉ុកប្រើឲ្យចូលរុនក្តាមសឹងចូលបាន ។

ដានី ៖ ឲ្យតែគាត់ប្រើទៅណា លោកតាត្រូវតែទៅ?

សាន ៖ ចឹងបានខ្ញុំពួក្មេងៗថាក្មេងឥឡូវ ផ្លូវឲ្យរឹងរកអត់ឃើញ ផ្ទះប៉ុនផ្ទះ ហើយរកផ្ទះអត់ឃើញទៀត ចុះប្រើខ្ញុំឲ្យមកវាយចាប ។ មកពីនោះមកមកវាយចាប ដើរកាត់ព្រៃ កាត់ភ្នំ ។

ដានី ៖ ភ្នំវាយចាប?

សាន ៖ បាទ!

ដានី ៖ គាម៉ុកក្រោយមក លោកតាដូចថាគាម៉ុកប្រើមក យើងត្រូវមក ។ ហើយស្នាដៃពេលប្រយុទ្ធកន្លែងណាក៏គាត់មិន....។ គាស៊ីនឹងក៏ជំនិតដែរ តែគាត់និយាយលង់ខ្លួនអាពេលឈ្នះហើយ ។ ឈ្នះហើយធ្វើសង្គ្រាមអត់ ត្រូវតែតស៊ូទៀត មុនតស៊ូអី ហើយឥឡូវតស៊ូអី វាច្រើនខ្ញុំភ្លេច...។ ចឹងខ្ញុំថាខ្ញុំមិនធ្វើចូលទេ ចឹងបានមិនលង់ពាក្យមកជាមួយហើយ ខ្ញុំខ្លាចចឹងបានខ្ញុំដកចេញ ចោទថាមានទោសមុនហើយ ដូចប្រពន្ធហើយនឹងប្ដីចឹង ។

សាន ៖ អូ! ចឹងគេចោទលោកតាថាមានទោសអី គាត់ចោទលោកតា?

ដានី ៖ មិនទាន់មានទេ វាអត់ឃើញភស្តុតាង ប៉ុន្តែគេដកចេញ ដល់ក្រោមៗខ្ញុំគេចាប់សម្លាប់ចោលអសលហើយ ។ បាទ! ចងទម្លាក់មក ដល់ខ្លាំងៗជំនាន់មុន អស់ច្រើនអស់៣ ។ ខ្មោចតាឡុំ ខ្មោចមិត្តរុន នឹងសុទ្ធគេ ។ ចឹងបានថារឿងស្លាប់នឹង គេមិនមែនស្លាប់ដោយសារតែអ្នកតស៊ូជាមួយអ្នកនេះ តស៊ូជាមួយនោះទេ វាហេតុផលមាន ។ ហេតុផលមានខ្ញុំដឹង ដូចដឹងតាស៊ីកងពលខ្ញុំធ្វើប្រធាន ។

សាន ៖ ចុះតាសឿងគេចាប់គាត់ដែរ គាត់ធ្លាប់ដែល ឬក៏?

ដានី ៖ អត់ទេ តាសឿង រឿងគ្នាឯងបាញ់គ្នាឯងទេ ។

សាន ៖ រឿងគ្នាឯងបាញ់គ្នាឯងទេ ។

ដានី ៖ រឿងគ្នាឯងបាញ់គ្នាឯង?

សាន ៖ បាទ!

ដានី ៖ បាញ់នៅណា?

សាន ៖ នៅអន្លង់វែង គេនៅ ។

ដានី ៖ ឆ្នាំណា?

សាន ៖ បាទ! ដឹងឆ្នាំប៉ុន្មាន គ្រាន់ថារឿងរ៉ាវទាំងអស់ យកសឿងពីភូមិភាគនិរតីមកខាងជើងនឹងវិញ បានឮថាគេបាញ់គាត់ ។

ដានី ៖ ក្រោយឆ្នាំ៧៩ហើយទេ?

សាន ៖ ក្រោយហើយ វៃជាមួយយួន វៃជាមួយអីហើយ ។

ដានី ៖ អូ! ចឹងទេ ។ ចុះលោកតា ចឹងពេលដែលបន្ទាប់ពីមុនមកដឹងថាការសម្លាប់នឹង ដូចលោកតាមានប្រសាសន៍មិញចឹង ដូចថាខាងក្នុងនឹងមាន២ មាន៣?

សាន ៖ បាទ! វាមាន២មាន៣ ។ ការសម្លាប់ចឹង សហករណ៍ខ្លះគេណែនាំមិនឲ្យមានមនុស្សអត់បាយ ប៉ុនហេតុផលអីដែល បង្អត់បាយចឹង ។ បើខ្ញុំនៅយោធាទេ ខ្ញុំមិនដឹងទេ តែយោធាអត់ដឹងទេ ព្រោះការងារដាច់ពីគ្នា បើកាលនោះពេលនោះដាច់ពីគ្នា សហករណ៍គឺសហករណ៍

យោធាគឺយោធា ។ ដល់ខ្ញុំទៅភ្នាប់វិញបានដឹង ។ ម៉េចបានអត់បាយ ដាំដំឡូងគេឲ្យដាំឲ្យដីក ស្ងោរឲ្យកូនស៊ីមុននឹង ពេលបាយបាន ទម្រាំដល់ពេលបាយ គ្នាទៅគាស់ដំឡូងគ្នា ថាគ្នាក្បត់បាញ់ចោលៗ ។ អានឹងវាមានវាមានសិទ្ធិពេក អាសិទ្ធិអ្នកសម្លាប់ អ្នកសម្លាប់នឹងតែ ២ទេ ទុកឲ្យខ្មោច រលួឲ្យនៅ ពាក្យនឹងប្អូនៗធ្លាប់ដឹងធ្លាប់ឮដឹងហើយ ។ ម៉េចហៅថា រលួឲ្យខ្មោ រោយឲ្យនៅ នឹងហើយធ្វើឲ្យឥទ្ធិពលៗអ្នកគ្រប់គ្រង ។ ហើយឯងអត់ដឹង ។

ដានី : ប៉ុនកាលនឹងបន្ទាប់ពីតាស៊ី គាត់គេចាប់ទៅ ចាប់តែតាស៊ីម្នាក់ ឬក៏ចាប់អ្នកផ្សេងទៀត នៅក្នុងគណៈភូមិភាគបស្ចឹម?

សាន : តែតាស៊ីមួយទេ ។

ដានី : តាស៊ីមួយ?

សាន : បាទ!

ដានី : ចឹងតាប៉ាល់ហើយពីណាមួយទៀត ដែលក្នុងគណៈភូមិភាគ?

សាន : អឺប៉ាល់ខាងឃុំខាងស្រុក សៀងខាងទ័ព ណាមួយទៀតទេ ខ្ញុំភ្លេច អឺ! រ៉ន ។

ដានី : រ៉ន?

សាន : បាទ!

ដានី : រ៉នមួយទៀត ។ ចឹងកាលនឹងតាស៊ី គាត់ក្បត់តែឯង?

សាន : មិនដឹង អារឿងក្បត់មិនក្បត់ ខ្ញុំមិននិយាយ ពីព្រោះខ្ញុំគ្រាន់តែដឹងថាគាត់បបួលខ្ញុំធ្វើសង្គ្រាមម្តងទៀត ខ្ញុំថា“ធ្វើសង្គ្រាមធ្វើ” ហើយខ្ញុំមិននិយាយរឿងអី ក៏ខ្ញុំអត់និយាយទេ ដល់គេដកខ្ញុំចេញ បានខ្ញុំដឹងខ្លួន អូ!តាស៊ីមកបបួលខ្ញុំធ្វើតែខ្ញុំអត់ធ្វើ បានតាស៊ីដកខ្ញុំចេញ ។

ដានី : ចឹងតំបន់លោកតា កំពង់ស្ពឺតំបន់៣៣ ចុះតំបន់កោះកុងតំបន់លេខប៉ុន្មាន?

សាន : ៣៧ ។

ដានី : ចុះតំបន់កំពង់ឆ្នាំង?

សាន : កំពង់ឆ្នាំង ៣៥ ហើយ៣០ប៉ុន្មានភ្លេច ។

ដានី : ចឹងនៅក្នុងតំបន់៣៣ លោកតា ហើយខាង៣៧ពីណាគេគ្រប់គ្រង?

សាន : អត់ស្គាល់ៗ ភ្លេចឈ្មោះអត់ហើយ ។

ដានី : ភ្លេចឈ្មោះ?

សាន : បាទ!

ដានី : ចុះលោកតាមានប្រសាសន៍មិញ ថាឈ្មោះរ៉ន គាត់ទៅ?

សាន : រ៉នទៅនឹង ទៅបានទៅមិនដឹងទៅជាមួយណាៗ ។

ដានី ៖ ចុះខាងកំពង់ឆ្នាំង?

សាន ៖ កំពង់ឆ្នាំង មើលក្មេចឈ្មោះមនុស្ស ឈ្មោះដើមក៏ភ្លេច អាឈ្មោះរាល់ថ្ងៃក៏ភ្លេច។

ដានី ៖ គាត់នៅណាឥឡូវ?

សាន ៖ ស្លាប់ហើយ ស្លាប់ទាំងអស់ មនុស្សដឹងពីកន្លែងនៅ ដឹងផ្ទះនៅ។

ដានី ៖ ផ្ទះគាត់នៅណា?

សាន ៖ ផ្ទះគាត់នៅភូមិពាមទាំងអស់។

ដានី ៖ ពាមដែរ?

សាន ៖ អឺ!

ដានី ៖ ចិនអឺ!

សាន ៖ មួយៗឈ្មោះ រ័ត្ន។

ដានី ៖ រ័ត្ន?

សាន ៖ អឺ! ឈ្មោះដើម ឈ្មោះរ័ត្ន។

ដានី ៖ ចិនតាសុត បន្ទាប់ពីគាត់នេះមក គាត់អត់មានមកគ្រប់គ្រងនៅភូមិភាគបស្ចឹមនេះទៀតទេ?

សាន ៖ អត់។

ដានី ៖ រៀបចំឲ្យ?

សាន ៖ បាទ!

ដានី ៖ លោកតាដូចថា គោលនយោបាយយើងបន្ទាប់ពីតាសុី ត្រូវបានគេចាប់ទៅចិនទៅ ដល់ពេលយើងរៀបចំដូចជាលោកតានៅក្នុងតំបន់អីគ្រប់គ្រងប្រជាជននៅរៀបចំ យើងធ្វើគោលនយោបាយអីយ៉ាងម៉េច ដូចថាយើងត្រូវ?

សាន ៖ អត់មានអី មានដឹងនាំឲ្យធ្វើស្រែធ្វើចំការ ដើម្បីរស់ប៉ុននឹង អត់មានគិតធ្វើអីទៀត មានគិតបង្កើនផលតាមតែដឹងធ្វើ ហើយនាំធ្វើ។ ចិនបានថាកន្លែងខ្លះដឹងហើយនាំធ្វើ មានគោលនយោយធ្វើម៉េចឲ្យមានហូបបានបាយម៉ាថ្ងៃ៣ពេល មានដំឡូង មានត្រាវ មានអីហូបជុំវិញចំការ ជុំវិញផ្ទះ ព្រោះដីយើងមាន។ ពាក្យមួយ ប៉ុល ពត ថា ដាំៗកុំឲ្យសល់ដី។ ស្រុកយើងពុទាំងអស់គ្នាទេអានឹង ប៉ុល ពត ថាដាំៗកុំឲ្យសល់ដីថាចិន ដាំទៅវាមានវិបត្តិចិន។ កន្លែងខ្លះវាធ្វើឲ្យខ្ទេច ធ្វើឲ្យប៉ះពាល់ដល់នយោបាយ វាមិនឲ្យស៊ីវាកាប់ដីសម្លាប់អីចិន។

ដានី ៖ ប៉ុនលោកតាដល់ពេលយើងទៅរៀបចំក្រោយនឹង ដូចថាប្រជាជនបានហូបចុកឆ្អែតគ្រប់គ្រាន់?

សាន ៖ អត់អី ។

ដានី ៖ អត់អីនេះ?

សាន ៖ អត់អី ភូមិភាគរបស់ខ្ញុំអត់មាន ។

ដានី ៖ លោកតានៅតំបន់៣៣នឹងមានស្រុកអីខ្លះទៅ ស្រុកដែលក្រោមតំបន់៣៣មានស្រុកអីខ្លះ?

សាន ៖ មានស្រុកភ្នំស្រួច វលាប្អៀរ ។

ដានី ៖ ស្រុកភ្នំស្រួច វលាប្អៀរ ស្រុក?

សាន ៖ ស្រុកថ្ពង ។

ដានី ៖ ស្រុកថ្ពង ស្រុកណាទៀត?

សាន ៖ គេចាត់តាំងស្រុកថ្មីនេះ ស្រុកឱរ៉ាល់ ។

ដានី ៖ ស្រុកឱរ៉ាល់ ស្រុកណាទៀត?

សាន ៖ ស្រុកនេះគេកាត់ឲ្យម៉ាចំហៀងដែរ ។

ដានី ៖ ស្រុកណា?

សាន ៖ កំពង់ឆ្នាំង កាត់ឲ្យកំពង់ត្រឡាចលើ ។

ដានី ៖ កំពង់ត្រឡាចលើម៉ាចំហៀងនឹង?

សាន ៖ អឺ! កំពង់ត្រឡាចលើ ។

ដានី ៖ ហើយស្រុកណាទៀត?

សាន ៖ តែប៉ុននឹងទេ ។

ដានី ៖ ចុះខាងច្បារមន ខាងគងពិសីអីមែនទេ?

សាន ៖ គងពិសី នៅម៉ាចំហៀងខាងជើងថ្នល់លេខ៤ទាំងអស់ ។

ដានី ៖ ទាំងអស់?

សាន ៖ បាទ! រហូតទៅទល់គ្នានឹងផ្លូវ២៦ ។

ដានី ៖ ចុះខាងបសេដ្ឋខាងអី?

សាន ៖ ខាងនោះខាងត្បូង ។

ដានី ៖ អានឹងខាងក្នុងតំបន់លោកតាដែរ?

សាន ៖ តំបន់សាម(៣០)១ ។

ដានី ៖ សាម(៣០)ប៉ុន្មាន?

សាន ៖ តំបន់៣៣ អូ! នែកខាងត្បូង ។

ដានី ៖ តំបន់ផ្សេងទៀត?

សាន ៖ បាទ! តំបន់ខាងត្បូង ។

ដានី ៖ ចឹងតំបន់៣៣របស់លោកតាមានភ្នំស្រួចម៉ាចំហៀង?

សាន ៖ បាទ!

ដានី ៖ ស្រុក?

សាន ៖ សំរោងទងម៉ាចំហៀង ។

ដានី ៖ សំរោងទងម៉ាចំហៀង ស្រុក?

សាន ៖ និយាយថាខាងជើងផ្លូវលេខ៤ ។

ដានី ៖ ខាងជើងផ្លូវលេខ៤?

សាន ៖ បាទ!

ដានី ៖ ម៉ាខាងជើងផ្លូវលេខ៤ ហើយមកដល់ខាងណាទៅ?

សាន ៖ មកដល់កំពង់ឆ្នាំងនឹង ។

ដានី ៖ មកដល់កំពង់ត្រឡាចលើនឹង?

សាន ៖ កំពង់ត្រឡាចលើ ។

ដានី ៖ កំពង់ត្រឡាចលើ មានស្រុកភ្នំស្រួចទាំងមូល អឺ!ស្រុកថ្ពងទាំងមូល ស្រុកកំពង់ត្រឡាចលើ ម៉ាចំហៀង ស្រុកភ្នំស្រួចម៉ាចំហៀង ស្រុក ។

សាន ៖ ស្រុកឧត្តុង្គ ។

ដានី ៖ ស្រុកឧត្តុង្គទាំងមូល?

សាន ៖ បាទៗ ។

ដានី ៖ ស្រុកគងពិសី ម៉ាចំហៀងដែរ?

សាន ៖ បាទ! គងពិសីម៉ាចំហៀង ភ្នំស្រួចម៉ាចំហៀង ។

ដានី ៖ ចឹងនៅភូមិភាគបស្ចឹមនឹង មានតំបន់៣៣ តំបន់៣៥ តំបន់៣៧ តំបន់ណាទៀត មានតំបន់ផ្សេងទៀតទេ?

សាន ៖ ហ៎! ខ្ញុំភ្លេចអាតំបន់កំពង់ឆ្នាំង ខ្ញុំកំពតនឹង៣៥កំពត ៣៣បាន អត់ចាំអស់ វាភ្លេចអស់ ។

ដានី ៖ បាទ! អត់អីទេ ។ ចឹងបន្ទាប់ពីលោកតាមកកាន់នៅតំបន់នឹង នៅឆ្នាំ បើឆ្នាំ លោកតាចាំឆ្នាំហ៎?

សាន ៖ ឆ្នាំដែលយួនបុកមកនឹង ៧៧ ។

ដានី ៖ ៧៧ ហេ៎?

សាន ៖ បាទ! ៧៧ ៧៨ ខ្ញុំកាន់បានពាក់កណ្ដាលចិន ម៉ាកំណាត់ម្នាក់ ។

ដានី ៖ បាទ! ម៉ាកំណាត់ម្នាក់ ពីមុនពីជំនាន់តាស៊ីម៉ាកំណាត់ ហើយជំនាន់លោកតាឃួនចូលម៉ាកំណាត់ទៀត?

សាន ៖ បាទ!

ដានី ៖ ចឹងលោកតាឃើញថា ពេលដែលលោកតាមកកាន់ពីចន្លោះ៧៧មក ដូចថាកាលនឹងអ្នកដែលកាន់ខាងគេមានខ្មែររបស់តាស៊ីខ្មែរៗ?

សាន ៖ បាទ! មាននឹងហើយ ដែលធ្វើឲ្យប្រជាជន ។

ដានី ៖ ចុះយើងធ្វើម៉េចវិញ យើងស្រាវជ្រាវធ្វើម៉េចទៅអានឹង?

សាន ៖ យើងហៅមកអប់រំ ស្ដីចឹង ដូចថាធ្វើស្ដីខុសចឹង យើងហៅមកអប់រំនៅសាលា ។

ដានី ៖ តែយើងដឹងខ្មែររបស់គាត់ យើងធ្វើម៉េចបានដឹង?

សាន ៖ ធ្វើខុសដឹង ។

ដានី ៖ តែធ្វើខុសដឹង?

សាន ៖ បាទ! ឧទាហរណ៍ថា ណែនាំឲ្យដាំឲ្យដុះធ្វើអីចឹង ដល់ធ្វើគ្នាទៅដកដំឡូងស៊ីអីចឹង គេប្រាប់ហើយ ។ តែដកដំឡូងស៊ី យកអ្នកនោះទៅវ៉ៃចោលមួយបាត់ហើយឃើញទេ ចឹងវ៉ៃ២ ។ ឃើញទេ អានោះហើយនឹងអ្នកថាដកដំឡូងស៊ី ថាក្បត់ វ៉ៃគ្នាចោល ។ បាទ! អានេះដឹងខាងលើដឹង ហើយមកអប់រំមិនស្ដាប់ ។ ចឹងវាអត់មានទុកដាក់អីចឹង អានឹងដែលស្លាប់ៗពេលនឹងចឹង អានឹងដែលខ្ញុំដឹងៗចឹង មិនមែនអត់ហេតុផល គេមានហេតុផល ។

ដានី ៖ អត់មានហេតុផលហេ៎?

សាន ៖ បាទ! អ្នកខ្លះគេថាសម្លាប់ដោយអត់ហេតុផល មិនមែនទេ ។

ដានី ៖ ហេតុផលនឹង ដូចថាអ្នកដែលដកដំឡូងនឹង?

សាន ៖ ហើយចុះយើងប្រជុំ យើងណែនាំឲ្យធ្វើចឹង ធ្វើជុំវិញផ្ទះ ដាំសម្រាប់កូនយាំ ដកដំឡូងដាំស៊ីហើយដល់លួចដល់អីគេដឹង គេដកយកមកសម្លាប់គ្នាអ្នកផ្ទះអ្នកអីចឹង ។

ដានី ៖ ចឹងដល់ពេលលួចទៅដកចឹង ដូចយើងអ្នកគ្រប់គ្រង?

សាន ៖ មិនមែនលួចទេ លួចគេដឹង លួចគេផ្សេងគេដឹង ហើយគេធ្វើសកម្មភាពថាអ្នកនឹងក្បត់ដកដំឡូងស៊ីតែឯង ខុសសមូហភាព ។ ដែលយកអាពាក្យសមូហភាពនឹង យកទៅបាញ់ចោល យកអីចឹងទៅ ។ ចឹងវាមានសិទ្ធិបាញ់ចោល នឹងវាចឹង ។

ដានី ៖ ចឹងកាលនឹងអ្នកដែលមានសិទ្ធិ ដែលថាគាត់ទោសអី ត្រូវទៅសម្លាប់ទៅអី អ្នក?

សាន ៖ មានច្បាប់មាន ។

ដានី ៖ ពីត្រឹមណា មកយើងមានសិទ្ធិ?

សាន ៖ ច្បាប់ទាល់តែខាងសេនាសធិការរបស់យោធា ។

ដានី ៖ សេនាធិការរបស់យោធា?

សាន ៖ បាទ! អានឹងរបស់មជ្ឈិម ។

ដានី ៖ របស់មជ្ឈិម?

សាន ៖ បាទ! សេនាធិការរបស់មជ្ឈិម ។

ដានី ៖ អាហ្នឹង អ្នកមានសិទ្ធិ?

សាន ៖ បាទ! មានសិទ្ធិហាម៉េច ហា ។

ដានី ៖ បានន័យថា ឲ្យតែកងទ័ពរបស់មជ្ឈិម ទោះជាអ្នកនឹងកូនទាហាន ក៏មានសិទ្ធិ?

សាន ៖ អត់ទេ បើមានសិទ្ធិសម្រេច សិទ្ធិដូចតំបន់ដូចអីចឹង មានសិទ្ធិតែផ្តល់យោបល់ទេ រាយការណ៍ ។ ដល់គណៈមជ្ឈិមនឹង បានគេអ្នកសម្រេចថាយ៉ាងណាៗ គណៈមជ្ឈិមជាអ្នកសម្រេច ។ តែអ្នកសម្រេចនឹង ខ្លះនឹងវាអត់ចាំបាច់មជ្ឈិមសម្រេចទេ វាចង់ធ្វើឲ្យខូចខាតអីចឹង វាសម្រេចខ្លួនវា ។ ដល់ហើយប៉ះពាល់ វាមិនខូចទាំងអស់គ្នា ។

ដានី ៖ ចឹងបើតាមលោកតាដឹង លោកតាធ្លាប់គ្រប់គ្រងនៅតំបន់ បើតាមការស្ដាប់ ហើយលោកតាប៉ាន់ស្មានមើល ប្រហែលប៉ុន្មានទៅ?

សាន ៖ ខ្ញុំមិនបានដឹងទេប្អូន ។

ដានី ៖ អត់ដឹង?

សាន ៖ បាទ! ព្រោះការវិនិច្ឆ័យខ្លួនខ្ញុំអត់ដឹង អត់មាន ។ ខ្ញុំសូម្បីធ្វើសង្គ្រាមម៉ាជំនាន់ក្រោយមកនេះ ខ្ញុំចាប់បានទៅសួរទៅមនុស្សនៅភ្នំសួយ ខ្ញុំចាប់បាន ។ ហឺ! ទាហាន ល្បិចហើយនឹងខ្ញុំ ។ ខ្ញុំមានល្បិចមួយចាប់មនុស្សរស់(សើច) ។

ដានី ៖ ល្បិចម៉េចទៅ?

សាន ៖ ល្បិច ក្អួយឯងកំពុងនៅអង្គុយដឹកស៊ីអីនឹង ខ្ញុំដើរទៅភ្ជង់កាំភ្លើង អត់ហ៊ានធ្វើអីខ្ញុំទេ ។ ដល់ចឹងចាប់បាន ខ្ញុំមិនចាប់បាន ក្លែងភេទ ។

ដានី ៖ ក្លែងភេទ?

សាន ៖ នឹង កាលនៅយួន ម៉ារីកធ្វើទាហានយួន មិនចាប់ទាហានខ្មែរបាន(សើច) ។

ដានី ៖ កាលនឹងលោកតាចាប់ ធ្វើអាល្បិចនឹងចាប់បានច្រើនទេ?

សាន ៖ ចាប់បាន ។

ដានី ៖ ចុះកាលពី លោកតាមគណៈតំបន់មក លោកតាមានធ្វើល្បិចនឹង ដូចថាគាត់អ្នកគ្រប់គ្រង នៅតាមស្រុកតាមឃុំអី ដែលគាត់ដូចថាដុតឲ្យខ្ទេច រោយឲ្យនៅ ។ ដល់ពេលចឹងយើងមាន ក្មេងដើម្បីចាប់គាត់ យើងហៅ?

សាន ៖ ខ្ញុំអត់ដែលចាប់ ដែលតែហៅ ។

ដានី ៖ ហៅមក?

សាន ៖ ហ្នឹងហៅមកហៅ ។

ដានី ៖ ហៅមកធ្វើម៉េច?

សាន ៖ ហៅមកអប់រំ ។

ដានី ៖ ហៅមកអប់រំ?

សាន ៖ បាទ! ខ្ញុំលែងទៀត បើខ្ញុំមកធ្វើតំបន់ ។ លែងទៅសួរអ្នកនៅភ្នំបាសិតក៏ខ្ញុំលែង ។

ដានី ៖ អូ! ចឹង ព្រោះកាលនឹងខ្ញុំធ្លាប់ដឹងដែរ មានគេហៅជំរំ?

សាន ៖ បាទ! ជំរំនៅភ្នំបាសិត នៅភ្នំយើងខាងជើងនេះនឹង ខ្ញុំទៅលែងនៅនឹងទាំងអស់ ។ ឥឡូវនឹង បើនឹងទៅជួប សុទ្ធលើកដៃសំពះ ខ្ញុំលែងគ្រប់តែកន្លែង ។

ដានី ៖ ចឹងនៅភ្នំបាសិតនឹង គ្រប់គ្រងរបស់ភូមិភាគបស្ចឹមទេ?

សាន ៖ បាទ!

ដានី ៖ ភ្នំបាសិត មានកន្លែងគេវៃថ្ម មានគុកមានអីនឹង?

សាន ៖ បាទៗ ។

ដានី ៖ អានឹងរបស់កន្លែងតំបន់ របស់លោកតា?

សាន ៖ ហ្នឹង ។

ដានី ៖ ចឹងលោកតាមកជួប កាលនឹងឃើញទ័ពនៅនឹងច្រើន?

សាន ៖ អត់ ។

ដានី ៖ អត់ទេ?

សាន ៖ អត់មានទ័ពណា អត់មានទេ ។

ដានី ៖ និយាយចឹង ចុះអ្នកទោសអីដែលគេចាប់មកច្រើន?

សាន ៖ បាទ! នៅ ។

ដានី ៖ លោកតាទៅប្រលែងនៅនឹងច្រើន?

សាន ៖ បាទ! លែងនៅភ្នំបាសិតក៏ខ្ញុំធ្លាប់លែង ទៅលែងនៅជ្រៃអូរញ្ញៅ ។

ដានី ៖ ជ្រៃអូរញ្ញៅដែរ?

សាន ៖ បាទ! ជ្រៃអូរញ៉ៅនឹងមានអ្នកនៅ អឺ! មកយកចិត្តធ្លាប់លែង ខ្ញុំភ្លេចភូមិ ខ្ញុំលែងឥឡូវនឹង ប៉ុនកាលនៅយូននឹងខ្ញុំទៅនៅលើភ្នំនឹងតាមចិត្ត នៅចុះតាមចិត្ត លាក់ខ្លួនបាន ព្រោះគាត់ធ្លាប់ហើយសុខចិត្តសុខ-ក សុខជាប់គុក ។ កាលខ្ញុំលែងកាលខ្ញុំនៅតំបន់នេះ ខ្ញុំលែងចាស់ៗ ខ្ញុំដើរតែលែង ។

ដានី ៖ ចុះអ្នកដែលដូចថា អ្នកប្រធានសន្តិសុខនៅតាមដូចថា នៅភ្នំបាសិត នៅជ្រៃអូរញ៉ៅអី លោកតាដែលជួបគាត់អីហៅមកអប់រំអីយ៉ាងម៉េចដែរ?

សាន ៖ ពេលខ្ញុំមក ខ្ញុំហៅមកកែលំអរ ។

ដានី ៖ ឈ្មោះអីទៅនៅភ្នំបាសិត?

សាន ៖ ភ្លេចហើយប្អូន ភ្លេចឈ្មោះ ។

ដានី ៖ ភ្លេចហ៎?

សាន ៖ បាទ!

ដានី ៖ នៅជ្រៃអូរញ៉ៅ ក៏?

សាន ៖ អត់ៗដឹង ភ្លេច... ។

ដានី ៖ ឆ្នាំណាដែលលោកតាទៅកន្លែងភ្នំបាសិត?

សាន ៖ អូ! អត់ចាំឆ្នាំ ប៉ុនធ្វើការបានប៉ុន្មានខែ ពាក់កណ្តាលឆ្នាំ៧៧ មក៧៨នោះបានកើត ។

ដានី ៖ ចុះតាមុកដែលចុះមកទៀតទេ កាលនឹង?

សាន ៖ អត់ទេ បែកគ្នាដាច់ចឹង អត់ដែល មានគាត់ទៅប្រជុំ ។

ដានី ៖ គាត់ទៅប្រជុំដែរ?

សាន ៖ បាទ! ទៅប្រជុំបានជួបគ្នា ប្រជុំភូមិភាគ ប្រជុំមជ្ឈឹមបានជួបគ្នា ។

ដានី ៖ អូ! ប្រជុំមជ្ឈឹម ប្រជុំនៅភ្នំពេញ?

សាន ៖ បាទ!

ដានី ៖ ចឹងទៅប្រជុំមជ្ឈឹម រយៈពេលប៉ុន្មាន ម៉ាខែទៅប្រជុំម្តង?

សាន ៖ ម៉ាខែ ៣ខែ តាមពេលគេហៅ ។

ដានី ៖ ប្រជុំនៅកន្លែងណា ហ្នឹងលោកតា?

សាន ៖ ស្តាត ។

ដានី ៖ ប្រជុំនៅស្តាតអូឡាំពិច?

សាន ៖ បាទ! ប្រជុំទាំងយោធា ទាំងតំបន់ ។

ដានី ៖ ហើយទាំងយោធាទាំងតំបន់ ភូមិភាគមកប្រជុំនឹងជាមួយគ្នា?

សាន ៖ បាទ!

ដានី ៖ ពីណាអ្នកធ្វើជាគណៈអធិបតីប្រជុំនឹង?

សាន ៖ ជួនអ៊ីតានួន ជា, ជួនអ៊ីតាប៉ុល ពត ។

ដានី ៖ តានួន ជា, តាប៉ុល ពត?

សាន ៖ អឺ!

ដានី ៖ គាត់ពេលដែលប្រជុំម្ដងៗ គេច្រើនតែនិយាយពីរឿងអី?

សាន ៖ និយាយពីរឿងគ្រប់គ្រង ។

ដានី ៖ និយាយពីរឿងគ្រប់គ្រង?

សាន ៖ ហ្នឹងហើយ ព្រោះកម្លាំងនៅជាប់កុំឲ្យវា ហើយមួយទៀតសេដ្ឋកិច្ច ដោះស្រាយសេដ្ឋកិច្ច ជូនប្រជាជនឲ្យបាននៅលើអ្នកដឹកនាំ ។

ដានី ៖ បាទៗ ដោះស្រាយសេដ្ឋកិច្ច ។ ចុះកាលនឹងគាត់មានដែលនិយាយរឿងដែលថាពួកក្រុម ដែលលោកតាមានប្រសាសន៍មិញ ក្រុម២ដែលក្រុមធ្វើអាដុតឲ្យខ្មោចរោយឲ្យនៅអី ខាង នឹងដូចថា ខាងតានួន ជា ខាងអី, ពេលដែលគាត់មកប្រជុំ គាត់មានខស្សាហ៍រំលឹករឿង នឹងដែរ?

សាន ៖ រំលឹក អាការងារទាំងអស់ធ្វើម៉េចកុំឲ្យសត្រូវលូកដៃបាននាំឲ្យ ខូចខាតផលប្រយោជន៍ ទាំង កម្លាំង នឹងនិយាយទាំងអស់ ។

ដានី ៖ និយាយប៉ុន្តែ គាត់មានដូចថាគាត់ចាត់វិធានការណ៍យ៉ាងម៉េច យើងត្រូវទប់ស្កាត់យ៉ាងម៉េច យើងត្រូវកំចាត់ពួកនឹងយ៉ាងម៉េច អីគេ ។ គាត់មានណែនាំ មានប្រាប់ឲ្យធ្វើ?

សាន ៖ អត់ មានឯកសារមើល ។

ដានី ៖ មើលតាមឯកសារ ។

សាន ៖ ហ្នឹង ។

ដានី ៖ ឯកសារអីគេទៅកាលនឹង?

សាន ៖ ឯកសារសេដ្ឋកិច្ចនឹងហើយ មានឯកសារសេដ្ឋកិច្ច ឯកសារនយោបាយ ពង្រឹកកម្លាំង ប្រព័ន្ធហ្នឹង ប្រព័ន្ធដឹកនាំ ។

ដានី ៖ ចុះឯកសារទង់ក្រហម?

សាន ៖ ទង់ក្រហម អានឹងរៀន អត់រៀនមហាជនទេ ។

ដានី ៖ អត់រៀនមហាជនវិញ?

សាន ៖ បាទ!

ដានី ៖ អានឹងបង្រៀនម៉េច អានឹង?

សាន ៖ មេកម្មាភិបាល ។

ដានី ៖ ហ្នឹងសម្រាប់ពួកកម្មាភិបាលអ្នករៀនទេ?

សាន ៖ បាទ! ចាប់ពីគណៈឃុំឡើងទៅ ។

ដានី ៖ គណៈឃុំឡើងទៅ អានឹងរៀនពីអានឹង?

សាន ៖ បាទ!

ដានី ៖ ចុះរៀន របៀបថារៀនពីកម្មាត់ខ្មាំង បោសសំអាតខ្មាំងអីយើងរៀនយ៉ាងម៉េច?

សាន ៖ ភ្លេចអស់ហើយ អត់ចាំ តែគ្រាន់ថា ជាទិសដៅ គឺថាពង្រឹងអានឹង ។ មានទិសដៅពង្រឹងយុវជនកុំឲ្យវាបាត់បង់ ។

ដានី ៖ អានឹងយើងរៀនជាមួយដូចថា លោកតានួន ជា, ជាមួយប៉ុល ពត អីនឹង យើងរៀនក្នុងរយៈម៉ាខែម្តង ឬក៏៣ខែម្តង?

សាន ៖ ៣ខែ ។

ដានី ៖ ៣ខែ យើងមករៀននៅស្អាត?

សាន ៖ បាទ! មករៀននៅស្អាត ។ ៣ខែបានទៅរៀនម្តង បើភូមិឃុំមក បានម៉ាខែម្តង តាមមកជួបតំបន់វា ។

ដានី ៖ ចឹងពីភូមិ ពីឃុំ ពីស្រុកអីនឹង ម៉ាខែម្តង មកប្រជុំ?

សាន ៖ តំបន់ ។

ដានី ៖ តំបន់?

សាន ៖ បាទ!

ដានី ៖ ហ្នឹងពេលដែលមកនឹង មកប្រជុំ គេរាយការណ៍ប្រាប់ពីការងារ ធ្វើការងារ ពីសកម្មភាពអីនឹង?

សាន ៖ បាទ!

ដានី ៖ ហើយខាងតំបន់យើងម៉េច?

សាន ៖ យើងផ្សព្វផ្សាយតែចំនុចខាងលើ៣មិញ ។

ដានី ៖ ខាងលើ៣ម៉េច ៣នឹងមានអីខ្លះ?

សាន ៖ ទី១ពង្រឹងការងារចាត់តាំងនៅភូមិឃុំ, ទី២គឺថាកុំឲ្យសត្រូវលួកបាន យើងត្រូវបេះសាមគ្គីគ្នា, ទី៤ គឺថាធ្វើម៉េចដោះស្រាយសេដ្ឋកិច្ចជីវភាពឲ្យប្រជាជនបាន គឺចុះក្នុងចលនាដែលបង្កបង្កើន ។ នឹងហើយកម្មាភិបាល ដែលមិនដិតដល់ វាខុះខាត ។ ពេលនោះ ធ្វើបាន

កន្លែងណាដែលបានៗ កន្លែងណាដែលមិនបានៗ គឺថាគេមានវិបត្តិមួយដូចពាក្យខ្លះថានៅស្រុកផ្សេង ជួបគ្នាទៅនិយាយខ្លះ មិនឲ្យប្រជាជនហូប ឲ្យហូបបបរហូបអី ដឹកស្រូវយកឲ្យអ្នកណា ឲ្យណែ អានឹងខ្ញុំ ឮតែគេនិយាយទេ យើងវាមិនច្បាស់ យើងយកជាផ្លូវការមិនកើត ។

ដានី : តែចំពោះក្នុងប្រជាជនដែលលោកតាគ្រប់គ្រងនឹង គឺអត់មានហូបបបរ អត់មានខ្វះខាតអីទេ?

សាន : វាខ្វះខាតដែរប្អូន ។

ដានី : ខ្វះខាត?

សាន : បាទៗ ដោយសារពេលដែលយើងបញ្ចប់សង្គ្រាមទៅ វាមិនទាន់រឹងដៃ រឹងជើង អត់ទាន់មានសម្ភារៈប្រើប្រាស់ មិនទាន់មានគោទឹមអីត្រឹមត្រូវណា មិនគ្រប់គ្រាន់បរិបូរពេក គ្រាន់ថាមិនឲ្យលំបាកពេក ប៉ុននឹង ។ ត្រូវហូបដំឡូង ហូបក្ដួច ខ្លះចឹងទៅផ្សំ រួមផ្សំ ។

ដានី : រួមផ្សំ?

សាន : ហ្នឹងហើយ ។

ដានី : ចឹងតាម៉ុក គាត់មកតាំងពីចុះមករៀបចំអីហើយ គាត់មិនដែលមកប្រជុំអីទៀត?

សាន : មក ពេលដែលយើងប្រជុំ ឧទាហរណ៍ថា៣ខែយើងមកប្រជុំតំបន់ម្ដងអីចឹង ហៅគាត់មកៗ ។

ដានី : គាត់មកភូមិភាគបស្ចិម?

សាន : បាទ! ហើយយើងអត់មានអីទាក់ទងគាត់ៗ អត់មក ព្រោះគាត់នៅជាសមាជិករបស់មជ្ឈិមដែរ ។

ដានី : គាត់ជាសមាជិកមជ្ឈិម?

សាន : បាទ! ហើយយើងជាសមាជិកមជ្ឈិមដែរ តែវាក្រោម(សើច) មិនមែនលើ ។

ដានី : ចឹងលោកតាកាលនឹង បើយើងជាគណៈតំបន់ យើងជាសមាជិកមជ្ឈិមដែរ?

សាន : បាទ!

ដានី : ចុះបើស្រុក មានដល់គណៈមជ្ឈិមដែរអត់?

សាន : អត់ ។

ដានី : ចឹងមានត្រឹមពីតំបន់ទៅ?

សាន : បាទ!

ដានី : តំបន់ ភូមិភាគ?

សាន ៖ បាទ!

ដានី ៖ អានឹងត្រឹមសមាជិកមជ្ឈឹម?

សាន ៖ បាទ!

ដានី ៖ ចុះមានសមាជិកអចិន្ត្រៃយ៍ខាងលើទៀត?

សាន ៖ អចិន្ត្រៃយ៍របស់មជ្ឈឹមមានប៉ុន្មាននាក់ខាងលើនឹង ។

ដានី ៖ មានប៉ុន្មាន?

សាន ៖ អត់ចាំ ។

ដានី ៖ អត់ចាំ?

សាន ៖ ដូច៩ ១២មិនដឹងទេ ខ្ញុំភ្លេចទៅ ពីដើមវាចាំ ឥឡូវអត់ទេ ។

ដានី ៖ ចុះដល់ពេលសមាជិកមជ្ឈឹមច្រើន?

សាន ៖ ច្រើន ។

ដានី ៖ ប៉ុន្មានទៅ?

សាន ៖ ៩មិនដឹង ១២មិនដឹង ។

ដានី ៖ អានឹងសមាជិកអចិន្ត្រៃយ៍របស់មជ្ឈឹម?

សាន ៖ អចិន្ត្រៃយ៍របស់មជ្ឈឹម ។

ដានី ៖ ដល់ពេលសមាជិកមជ្ឈឹម ប៉ុន្មាននាក់ទៅ?

សាន ៖ សមាជិកមជ្ឈឹម តាមតំបន់មួយៗ គ្រប់តំបន់ អានឹងជាសមាជិករួម ។

ដានី ៖ ចុះលោកតាមួយទៀត ទាក់ទងនឹងប្រជាជន១៧ មេសា ហើយបើតាមខ្ញុំដឹង តាមពុថា កាលនឹងដូចថាមានការស្លាប់អីច្រើនចឹង?

សាន ៖ ស្លាប់ប្អូន វាចាញ់ ។

ដានី ៖ ចាញ់?

សាន ៖ បាទ! គ្រុនចាញ់ ។

ដានី ៖ គ្រុនចាញ់?

សាន ៖ គ្នានៅភ្នំពេញនៅអី ហើយមកនៅយកទៅដាក់តំបន់ឲ្យមានស្រែ មានចំការ តំបន់ព្រៃ ហើយគ្នាគ្រុនចាញ់ ។

ដានី ៖ គ្រុនចាញ់ច្រើន?

សាន ៖ បាទ! តែមកខាងខ្ញុំអត់សូវមាន ។

ដានី ៖ អត់សូវមាន?

សាន ៖ បាទ! មានត្រឹមទួលលាភ ត្រឹមអីនឹងមក ទៅវិញចុះទៅវិញឈ្មោះ ខ្ញុំដាក់មនុស្សនឹងទៅផ្ទះគេវិញ ចឹងអត់សូវមាន។ ភាគច្រើនទៅខាងពាយ័ព្យ ពួកនឹងចេញពីក្រុង។

ដានី ៖ អូ!ខាងពាយ័ព្យ លោកតាមានដឹងរឿងខាងពាយ័ព្យច្រើនទេ?

សាន ៖ អត់ទេ ដឹងថាទៅ។

ដានី ៖ ស្គាល់តាញឹមដែរអត់?

សាន ៖ ថីមិនស្គាល់។

ដានី ៖ ស្គាល់ដែរ គាត់ធ្លាប់ធ្វើការជាមួយតា?

សាន ៖ ធ្លាប់មក ដែលតាម៉ុកឲ្យនឹង ជួបគាត់៣ខែ នាំទៅវិញ ហើយអត់អន្ទរទៅ។

ដានី ៖ ចឹងលោកតាធ្លាប់មកពាយ័ព្យ តាម៉ុកឲ្យមកដែរ?

សាន ៖ បាទ!

ដានី ៖ មកឆ្នាំណា?

សាន ៖ មកអានឹងមកវែងណាស់ មកតាំងរដ្ឋប្រហារ។

ដានី ៖ អូ! មកតាំងរដ្ឋប្រហារ?

សាន ៖ បាទ! មក៣ខែ។

ដានី ៖ មកនៅណាទៅ?

សាន ៖ នៅភ្នំបាក់។

ដានី ៖ ភ្នំបាក់?

សាន ៖ អាភ្នំបាក់នេះ មិនវាលចាបគេវៃបាក់បែកមក មិននៅភ្នំបាក់ៗយើងជិតល្វាងនេះ។

ដានី ៖ ជិតស្រុកវវាង ខេត្តពោធិ៍សាត់?

សាន ៖ អត់ទេ ជិតអាល្វាងផ្លូវបទមក ភូមិល្វាង។

ដានី ៖ ភូមិល្វាង?

សាន ៖ បាទ!

ដានី ៖ ជួបជាមួយគាត់នៅនឹង ៣ខែនៅជាមួយគាត់៣ខែ?

សាន ៖ បាទ! នៅតែលើភ្នំនឹង ដឹងគាត់នៅណាទេ ហើយខ្ញុំនៅនឹង។ មកនៅនឹងដើម្បីឆ្លងទៅ។

ដានី ៖ ទៅធ្វើការជាមួយគាត់?

សាន ៖ ទៅត្បូងវិញ នៅរកយកអន្ទរ យកអី នៅខាងជើងវាលចាប នៅប្រមូលអន្ទរប្រមូលអីបានៗទៅ។

ដានី ៖ ចឹងនឹងនៅតាំងពីរដ្ឋប្រហារម៉េច?

សាន ៖ បាទ!

ដានី ៖ រដ្ឋប្រហារតាំងពីឆ្នាំ៧០?

សាន ៖ បាទ! ក្រោយឡើងអត់ដឹងទេ តាញ៉ឹមនៅណាៗអត់ដឹង។

ដានី ៖ តាញ៉ឹម កាលនឹងមានគណៈខាងជាមួយតាញ៉ឹម ពីណាខ្លះ?

សាន ៖ គេហៅមិនហៅចឹងគេហៅ តាទាត់ តាទះ។

ដានី ៖ ហៅតាអី?

សាន ៖ តាទាត់ តាទះ តាមួយដែលនិយាយជិតទាត់ម៉ាជើងផ្ទង តាមួយដែលនិយាយនៅជិត ទះឡើងទូង។

ដានី ៖ តាណាអ្នកទាត់ តាញ៉ឹមនឹង?

សាន ៖ តាញ៉ឹម។

ដានី ៖ តាញ៉ឹម អ្នកទាត់?

សាន ៖ បាទ! តាទាត់។

ដានី ៖ តាទាត់?

សាន ៖ បាទ!

ដានី ៖ ចុះតាទះ?

សាន ៖ តាទះ ដឹងឈ្មោះអី ខ្ញុំភ្លេចហើយ។

ដានី ៖ មិនមែនតាគឺហេ៎?

សាន ៖ អូ! តាគី នឹងហើយ។

ដានី ៖ តាគី?

សាន ៖ បាទ!

ដានី ៖ ហ្នឹងទះ ឲ្យតែនិយាយជាមួយគាត់ គាត់ទះយើង?

សាន ៖ បាទ! អង្គុយនៅជិតចឹង តែត្រូវរឿងអីឪបនឹងខ្នងយើងនឹងឥឡូវហើយ ហ្នឹងតាទះ។

ដានី ៖ ហ្នឹងតាទះ?

សាន ៖ បាទ! តាទាត់នោះ តែនិយាយនៅជិតនៅឈរ តែទាត់ម៉ាជើងបានគាត់និយាយតទៀត។

ដានី ៖ អូ! ហ្នឹងតាញ៉ឹម?

សាន ៖ បាទ! ចឹងឈ្មោះ២នឹង គឺគាត់ចឹងៗ គេដាក់ងារគាត់ទៅចឹងទៅ តាទាត់ តាទះ។

ដានី ៖ ចឹងមក លោកតានៅជាមួយគាត់ មកធ្វើការអីជាមួយគាត់ ៣ខែ នៅភ្នំបាក់នេះ?

សាន ៖ អត់ទេ គាត់នៅណានេះ ខ្ញុំមិនដឹងនៅណាផង គ្រាន់ថាមកជួប។

ដានី :	មកជួបគ្នានៅភ្នំបាក់?

សាន :	បាទ!

ដានី :	តែដល់ពេលឆ្នាំ៧៧ ៧៨ ដែលតាញឹម គេចាប់គេអីដែរនឹង?

សាន :	អត់ដឹងទេ ។

ដានី :	អត់ដឹងទេ?

សាន :	បាទ!

ដានី :	ខាងតាម៉ុកអីទៅ?

សាន :	បាទ! អត់ដឹង ។

ដានី :	ចុះតានួន ជា, តាខៀវ សំផន, គាត់ដែលចុះទៅតំបន់លោកតាដែរ?

សាន :	ទៅតើ ព្រោះគាត់ទៅឱរ៉ាល់ ។

ដានី :	គាត់ទៅឱរាល់?

សាន :	បាទ!

ដានី :	ឆ្នាំណាគាត់នៅឱរ៉ាល់?

សាន :	តាំងពី៧០ ៧២ ៧៣ មកនេះ តាហ្នឹងនៅនឹង ។ ហើយគាត់ចេញពីក្រុងរបស់គាត់នៅនឹង ។

ដានី :	ប៉ុន្តែចន្លោះពី៧៥ ៧៦ ៧៧ ៧៨អី គាត់ដែរទៅ?

សាន :	អត់ទេ ។

ដានី :	អៀង សារីអី គាត់ លោកតាអៀង សារី ប្រពន្ធគាត់អី?

សាន :	បាទ! គាត់នៅស្រុកខ្ញុំ គាត់ចេញពីក្រុងមកនៅ ។

ដានី :	គាត់នៅនឹង កាលនឹងកាលសម័យយើងតស៊ូ កាលពី?

សាន :	បាទ! ៧១ ៧២ គាត់នៅនឹង ។

ដានី :	គាត់នៅនឹង ប៉ុន្តែកាលនឹងលោកតាអីនៅទាក់ទងជាមួយគាត់ដែរ?

សាន :	អត់ ព្រោះការងារគាត់ផ្សេង ខ្ញុំការងារខាងយោធា អត់មានបានមកជិតគាត់ទេ ។

ដានី :	អត់ដែលបានមកជិតគាត់ទេ?

សាន :	បាទ! យោធានៅតែសមរភូមិមុខៗ ក្របខ័ណ្ឌជិតៗ ។

ដានី :	ប៉ុន្តែពេលទៅប្រជុំនៅស្តាតអី ពួកគាត់ចូលរួមទាំងអស់?

សាន :	បាទ! បើឈ្នះហើយទៅចូលខ្លួន ជួបគ្នាទាំងអស់ ។

ដានី :	ដល់ពេលឈ្នះហើយ ចូលរួមទាំងអស់?

សាន ៖ បាទ!

ដានី ៖ ចុះលោកតាដល់ពេល ចំមើលដល់ពេលយើង មិនវៀតណាមគេវ៉ៃចូលមកឆ្នាំ៧៩?

សាន ៖ បាទ!

ដានី ៖ ចឹង ដល់ពេលនឹងយើងចូលមកយ៉ាងម៉េចទៅ យើងម៉េចទៅ យើងដក?

សាន ៖ ខ្ញុំអត់មានទ័ពអីទេ ។

ដានី ៖ អត់មានទ័ពទេ?

សាន ៖ បាទ! នៅលើខ្នងភ្នំឱរ៉ាល់ ។ ដកមកនៅ រត់ៗមកនៅអស់បាយអស់ទឹកមកនៅលើ ខ្នងភ្នំឱរ៉ាល់ម៉ាឆ្នាំ ។

ដានី ៖ ម៉ាឆ្នាំ?

សាន ៖ ចឹងបានថាហូបមើមឈើ រស់សម័យ...បាន ហូបដំឡូង ហូបក្តួច ។

ដានី ៖ នៅភ្នំឱរ៉ាល់ម៉ាឆ្នាំ?

សាន ៖ បាទ!

ដានី ៖ កាលនឹងមានគ្នាប៉ុន្មាននាក់?

សាន ៖ ៦០ជាង ។

ដានី ៖ សុទ្ធតែយ៉ាងម៉េច សុទ្ធតែគណៈតំបន់?

សាន ៖ អត់ទេ សុទ្ធតែក្មេងៗប្រមូលមករត់ដាច់ដោចពីនេះពីនោះ ទៅចាត់ទុកឲ្យដឹកនាំដឹកដំឡូង ដឹកអី អត់មានគណៈតំបន់ គណៈស្រុកអីទេ ។

ដានី ៖ លោកតា កាលនឹងប្រពន្ធកូនអត់មកជាមួយ?

សាន ៖ អត់ទេ នៅតែខ្ញុំ ។

ដានី ៖ នៅតែលោកតាតែឯង?

សាន ៖ បាទ! នៅចៅៗក្មួយៗតូចៗ ។

ដានី ៖ ហើយម៉េចទៀតទៅ នាំ?

សាន ៖ ទៅដល់ ខ្ញុំដឹកដាំចំការ ។

ដានី ៖ បាទ?

សាន ៖ ធ្វើកាប់ចំការ កាប់អី ដាំហូបនៅនឹង មានធ្វើអីទៀត អត់ធ្វើអី ។

ដានី ៖ ម៉ាឆ្នាំ?

សាន ៖ បាទ! ម៉ាឆ្នាំ ។

ដានី ៖ ហើយម៉េចទៀតទៅ ចេញពីឱរ៉ាល់មកណា?

សាន ៖ ចេញពីឪវ៉ាល់ចុះទៅមើលភូមិ ចុះទៅជួបអ្នកនៅភូមិនឹង គេមកដល់ព្រំដែនដល់អី គេរៀបចំកម្លាំងរៀបចំអីចុះទៅវិញ ខ្ញុំទៅជួបគេនឹង ។ រៀបចំចុះទៅធ្វើការតាមភូមិតាមឃុំវិញ ។

ដានី ៖ បាទ! អានឹងដល់ពេលនឹងលោកតានៅម្តុំណាទៅ?

សាន ៖ នៅភ្នំស្រួច ។

ដានី ៖ នៅភ្នំស្រួច?

សាន ៖ បាទ!

ដានី ៖ កាលនឹងលោកតានៅទទួលបន្ទុកអីទៅ កាលនៅភ្នំស្រួច?

សាន ៖ ទទួលបន្ទុកខាងទាំងអស់ ដែលគេចែកចឹង ទាំងអស់ត្រូវទៅ ទាំងការងារប្រជាជនទាំងអស់ម៉ង ទាំងយោធា អប់រំប្រជាជនស្អីៗនឹង កសាងកម្លាំង ។ ហើយអត់មានទទួលដោយឡែកទេ ។

ដានី ៖ ទទួលទិសពីត្រឹមណាដល់ត្រឹមណា យើងមានទិស?

សាន ៖ ម៉ាស្រុកភ្នំស្រួច ។

ដានី ៖ ម៉ាស្រុកភ្នំស្រួច?

សាន ៖ បាទ!

ដានី ៖ នឹងពីឆ្នាំណាដល់ឆ្នាំណា?

សាន ៖ ៧៨ ៧៩ ។

ដានី ៖ បាទ? បែក៧៩?

សាន ៖ ពេល៧៩ហើយ ។

ដានី ៖ ៧៩ហើយយ៉ាងម៉េចទៀត?

សាន ៖ ៧៩ ខ្ញុំទៅដល់នោះ ៨១ ៨២ក៏នៅនឹងរហូត អត់មានធ្វើអី ។

ដានី ៖ ៨១ ៨២នៅនឹងដែរ?

សាន ៖ អឺ!

ដានី ៖ ដល់៨៣?

សាន ៖ ៨៣ក៏នៅនឹង ខ្ញុំមកនេះដល់៨៧ហើយបានមក ។

ដានី ៖ ៨៧ បានចេញពីភ្នំស្រួចមក?

សាន ៖ បាទ!

ដានី ៖ មកណាមក?

សាន ៖ មកនឹង មកនៅនឹង ។

ដានី ៖ មកនៅណា?

សាន ៖ នៅភូមិត្បូង ដ្ឋីកជ្រុំ ។

ដានី ៖ មកនៅ ជុបច្រើន ឈើទាលជ្រុំនឹង?

សាន ៖ បាទ!

ដានី ៖ មកនៅនឹង ធ្វើអីទៅ កាលនឹង?

សាន ៖ មកនៅនឹង មានកម្លាំងប៉ុននឹង ៣-៤... ២០-៣០ គ្រួសារ ។

ដានី ៖ កាលនឹងលោកតាមកដ្ឋីកជ្រុំនឹង មិនមែនឈប់ អត់មានធ្វើកង់ទ័ពអីទៀតទេ?

សាន ៖ អត់ទេ ។

ដានី ៖ អត់ទេ?

សាន ៖ បាទ! នៅនោះបានធ្វើ នៅនោះមានទ័ពក្តាប់នៅភ្នំស្រួចនឹង ។ ដល់សមាហរណកម្មហើយ ត្រូវនៅនេះ ព្រោះនៅនោះវាដីក៏អត់មិនចឹង ស្រែចំការអីវាគ្មាន ចឹងបើយើងទុកកម្លាំងនៅនោះទាំងអស់ វាខ្វះបស័គ្គរឿងអត់ដី អត់ទឹកប្រើប្រាស់ទេ ។

ដានី ៖ ចឹងលោកតាមកពីភ្នំស្រួចមកនេះឆ្នាំ៨៧ ដ្ឋីកជ្រុំនឹង?

សាន ៖ បាទ! សមាហរណកម្ម ។

ដានី ៖ សមាហរណកម្មហើយ?

សាន ៖ បាទ!

ដានី ៖ សមាហរណកម្មហើយ ឆ្នាំ៩០ជាងហើយលោកតា?

សាន ៖ អត់ទេ ។

ដានី ៖ ៩៦ ៩៧ សមាហរណកម្ម?

សាន ៖ បាទ!

ដានី ៖ មិនមែន៨៧?

សាន ៖ បាទ! ៩៧ ។

ដានី ៖ ៩៧ បានមកចឹង?

សាន ៖ បាទ! ខ្ញុំនៅភ្នំស្រួចនឹងរហូត ។

ដានី ៖ ក្រែងនៅកំពង់ស្ពឺនឹង កែវ ពង្ស គាត់អ្នកគ្រប់គ្រង?

សាន ៖ អត់ទេ កែវ ពង្ស ខ្ញុំគ្រប់គ្រង ។ កែវ ពង្ស គេឲ្យចុះពីនឹងទៅៗជួយការងារនឹងទេ ចឹងគេទទួលទាំងអស់វិញ ។ នែក! កំពង់ឆ្នាំង កំពង់ស្ពឺ ម៉ាផ្នែកខាងជើងនឹង កែវ ពង្ស អានឹងដូចកងពិសេស ។

ដានី ៖ បើតាមនេះទេ លោកតាទេ ដែលនៅនឹង?

សាន ៖ បាទ! កែវ ពង្ស ចុះទៅនាំទៅឥទ្ធិពលទៅ បាញ់គោគេស៊ី ចាប់រទេះគេដុតអីទេ ។

ដានី ៖ អូ! អាហ្នឹងកែវ ពង្សទេ?

សាន ៖ បាទ! រឿងខ្ញុំអត់ទេ តែសួរអ្នកស្រុក ខ្ញុំទាហាន ខ្ញុំមានប្អូនរាប់អានមួយដល់ថ្ងៃនេះ រឿងវិបត្តចាប់ឡានគេ ។

ដានី ៖ ពីណាគេចាប់?

សាន ៖ ខ្ញុំ ។ គេដឹកឈើឃើញទេ ខ្ញុំថាកុំឲ្យយោធាយកមក មកដឹកៗទៅ ហើយយកយោធាទាស់គ្នាៗ ។ យោធាមក ខ្ញុំដេញចាប់យោធាទៅ ទុកនឹងវាខ្លាចខ្ញុំ តែការពិតទៅ វាដឹងតែឲ្យតែខ្ញុំវៃវារត់ហើយ ។ ហើយចឹងកំហែងឯងរត់អស់ ចាប់ឡាន ឲ្យអាដែងទៅដឹកឈើនៅក្នុងព្រៃ ដេញអាមុខនេះរត់អស់ ។

ដានី ៖ ពីណាគេឈ្មោះអីនឹង?

សាន ៖ បាទ! កុំដាក់ឈ្មោះគាត់ ។

ដានី ៖ កុំដាក់ឈ្មោះ ។ ឆ្នាំពេលណាដែលលោកតាចាប់ឈើ?

សាន ៖ ដឹងឆ្នាំប៉ុន្មានបងប្អូន អត់ចាំ ។ ចាប់ទាល់តែមកលោះឡានៗ និយាយគ្នា ជួបមុខគ្នា ។

ដានី ៖ នៅកន្លែងណា?

សាន ៖ នៅត្រែងត្រយឹង ។

ដានី ៖ នៅត្រែងត្រយឹង?

សាន ៖ បាទ! ខាងជើងត្រែងត្រយឹងក្នុងព្រៃ ជួបគ្នាដេកជាមួយគ្នា និយាយជាមួយគ្នាហើយយកឡានយកអីទៅ ។ ដល់យកឡានអាដេកចេះនៅជិតឡាន ថា *"ហៅ!ដឹងជិតចឹងមកយកបាត"* ។ *"ឯងថាមកយកគ្រាប់កាំភ្លើង អញអត់ឲ្យ"* ។ បើមកចេះឲ្យ ។

ដានី ៖ គាត់អ្នកនៅខាងក្នុង?

សាន ៖ បាទ! ...កុំនិយាយនាំខូចឥទ្ធិពលគាត់ កុំនិយាយ ។

ដានី ៖ ឆ្នាំណានឹង?

សាន ៖ បាទ! អត់ចាំឆ្នាំទេ ប្អូន ។

ដានី ៖ លោកតា បើតាមលោកតាយល់វិញ កាលពី៣ឆ្នាំនឹង ការស្លាប់ ការដូចថា...នឹង បើតាមលោកតាសន្និដ្ឋានមើល ស្លាប់ដោយសារមូលហេតុអីច្រើន?

សាន ៖ មូលហេតុដោយសារ ការប្រឆាំងគ្នានឹងទេ ។

ដានី ៖ ប្រឆាំងគ្នាយ៉ាងម៉េចទៅ?

សាន ៈ ប្រឆាំងគ្នា អារឿងថាគណៈបក្សនេះ មួយចូលបក្សនោះទេ អាមួយយួន អាមួយខ្មែរនឹងទេ ។

ដានី ៈ ពីព្រោះកាលនឹងយើងកម្មាភិបាលទាំងអស់គ្នា មាន?

សាន ៈ ខ្លះយួន ខ្លះខ្មែរចេញ អានឹងគណបក្សដែលចូលវ៉ៃក្នុង៧០ឡើងមកនឹង ។ ចឹងមានគណបក្សខ្លះមកពីបារាំង ។ ឃើញទេ សូម្បីតែខៀវ សំផន ក៏បារាំង ។

ដានី ៈ បាទ! តាខៀវ សំផន បារាំង, អៀង សារី បារាំង?

សាន ៈ អាដែលនែក! អឺ! ស្អីៗធំៗដែលរដ្ឋមន្ត្រីកាលនឹងដែរ តាអីហ្នឹងមក ។ បែកដល់អាក្នុងស្រុកនេះ ពេលយួនចូលមកពីឆ្នាំ៥៨ សន្និសិទហ្សឺណែវ មិនយួនដកទ័ពទៅវិញ មិនមានគណបក្សឥណ្ឌូចិនៗនឹងមានទាំងអស់ សូម្បីតែផលនឹងក៏គណបក្សឥណ្ឌូចិនដែរ ដែលខ្ញុំដឹង ។ ខ្ញុំនឹងក៏គណបក្សឥណ្ឌូចិនដែរ ឃើញទេ សម្ព័ន្ធយុវជនបក្សឥណ្ឌូចិនដែរ ។ តាស៊ីនឹងក៏គណបក្សឥណ្ឌូចិនដែរ ។

ដានី ៈ តាណា?

សាន ៈ តាស៊ី ។

ដានី ៈ តាស៊ី តាដូ ដេត ហៅស៊ី ។

សាន ៈ បាទ! តាមួយទៀត តាចាន់ ដឹងស្អីចាន់ គាត់ខ្មើយ ។

ដានី ៈ គាត់ខ្មើយ?

សាន ៈ បាទ! ដឹងគាត់នៅណា វង្វេរគេលេងយំដូចកូនក្មេងចឹងតាចាន់ អ្នកណាទៀត ខ្ញុំភ្លេចអស់ ។ ខ្មោចស្រស់ តាស្រស់ អានឹងដែលដឹង ដែលមិនដឹងទៀតដឹងខាងណាខ្លះប៉ុនគេមាន២ចឹង ៣-៤នោះ បក្សបារាំង ខ្លះមកពីបារាំង ខ្លះមកពីគណបក្សពីយួនៗ អាប៉ុន្មានពាន់នាក់ដែលទៅពីឆ្នាំ៥៨ ៥៥ មកវិញ ។

ដានី ៈ យួនខាងជើង?

សាន ៈ បាទ! មកវិញៗមិនគណបក្សនេះផ្សាយខ្លួនទៅជាគណបក្សប្រជាជនវិញហើយ លែងគណបក្សឥណ្ឌូចិនហើយឃើញទេ ។ ដល់ចឹងវា គេប្រជុំពីឆ្នាំប៉ុន្មានៗ ខ្ញុំមិនចាំ ដល់ហើយគេកាត់អានឹងទៅ វាទៅជាគណបក្សប្រជាជន ។ អ្នកមកពីភាគខាងជើង មកពីហាន់ណូយនឹងមកៗគេចង់ត្រួតត្រាទាំងអស់ ខ្មែរឃើញទេ អាខ្មែរនៅក្នុងប្រទេស ។ ចឹងទាស់គ្នាដោយសារអានឹង ។ ចឹងបានន័យថាស្លាប់រស់កម្ពុជា មិនមែនន័យថា អត់.......ទេ ន័យថាមកពីទំនាស់ និងការឈ្លានពាន ។

ដានី ៈ អត់ទុកចិត្តគ្នា បាទ?

សាន ៖ ទំនាស់ និងការឈ្លានពាន។ មិនមែនមិនទុកចិត្តគ្នាទេ។ អាមួយមិនចង់ឲ្យគេត្រួតត្រា និងការឈ្លានពានរបទេសទេ ម្នាក់ទៀតគឺថានៅក្នុងការគ្រប់គ្រងនៃបរទេស ចឹងពីងបរទេស។ឃើញទេ ចឹងឈ្នះហើយត្រូវពឹងបរទេសទៀត អានឹងន័យចឹង បានយកយួនមកវ៉ៃខ្មែរទៀត។

ដានី ៖ បាទ! ខ្ញុំយល់។

សាន ៖ ខ្ញុំប្រាប់ប្អូនឯងឲ្យច្បាស់តែប៉ុននឹង ហើយខ្ញុំដឹងអានឹងដឹងច្បាស់ៗចាន់ ស៊ី មកប្រាប់ខ្ញុំចឹង។

ដានី ៖ គាស៊ីនឹងមកប្រាប់?

សាន ៖ បាទ! អ្នកប្រាប់ បបួលវ៉ៃទៀត វ៉ៃអ្នកឈ្នះនឹងហើយ ព្រោះឈ្នះមុនយួន ឃើញទេខ្មែរមិនឈ្នះមុនយួន។ មិនចឹងយួនគេមិនធ្វើរៀមច្បង ដល់យើងឈ្នះមុន យើងមិនរណបខ្លួនទេ ឃើញទេ។ ប៉ុល ពត ដាក់ថាមិនរណបបរទេសណាទាំងអស់ ឃើញទេ។ ដល់ចឹងវាខុសពីបំណងរបស់យួនដែលត្រូវត្រួតត្រាខ្មែរ ជួយប៉ុន្មានដងហើយឃើញទេ។ ៥៤ក៏យួនមក ឲ្យខ្មែរមានសង្គ្រាមយួនមកហើយ។ ឲ្យពេលនេះទៀត ក៏យួនមក។ ហើយយួនខាងត្បូង អាពួកនេះនឹង គ្នាអត់ដឹងអីគ្នា យួននៅក្រោមរបស់អាណានិគមន៍បារាំង អាណានិគមន៍របស់អាមេរិចនឹង។

ដានី ៖ ចុះលោកតា ប្រជាជនៗក៏ច្រើនដែលស្លាប់។ អ្នកខ្លះស្លាប់ដូចថាស្លាប់ដោយសារជម្ងឺ ដូចថាគ្រុនចាញ់ ដូចអី?

សាន ៖ បាទ! អានឹងស្លាប់ អូ!ស្លាប់រាប់មិនអស់ទេ ប្អូន អានឹង...។

ដានី ៖ ហើយមួយទៀតគេថាគាត់ ដូចថាគាត់អ្នកចេះដឹងបញ្ញាវ័ន្តអីយ៉ាងម៉េចៗ?

សាន ៖ អានឹងខ្ញុំអត់ដឹងទេ មិនដឹងថាមកពីយើងកាលនោះយើងនៅដោយទ័ព ហើយយើងចេញពីទ័ពមកវិញ យើងអត់បានគ្រប់គ្រងទៅតាមកន្លែងផ្សេងៗទេ។ ចឹងយើងគ្រប់គ្រងតែកន្លែងរបស់យើង តែកម្លាំងរបស់យើង។ ហ្នឹងកម្លាំងរបស់យើង បើយើងធ្វើអី យើងធ្វើខុសយើងដឹងខ្លួនយើង។ ចឹងខ្ញុំមិនឲ្យមានឥទ្ធិពលទេ បានន័យថាពាក្យតែមួយៗម៉ាត់ទេដែលខ្ញុំដកខ្លួនចេញពីនោះមកនេះ មកពីអី? មិនឈ្នះដោយខ្លួនយើង មិនបានអំណាចគ្រប់គ្រងដោយខ្លួនយើង ចឹងលើគេចាត់ចែង យើងអត់មានសិទ្ធិចាត់ចែងចឹង ឃើញទេ។ ចឹងខ្ញុំខ្លួនពីនោះ និយាយប្រាប់ឲ្យត្រង់ប៉ុននឹង។

ដានី ៖ លោកតាដកខ្លួនមក ដូចថាកែវ ពង្ស គាត់មានឥឡូវ ដល់ពេលគេសមាហរណកម្ម គាត់មានតួនាទីមានអី?

សាន ៖ គួនាទី អត់បញ្ហាទេ ប៉ុន្តែយើងនិយាយថា ផលប្រយោជន៍អីដើម្បីប្រជាជន ស្រែ ចំការ ទឹកដី ព្រៃដំណាំអីមិនឲ្យប៉ះពាល់ចិន។ គេមានសិទ្ធិគ្រប់គ្រង គេមានសិទ្ធិចាត់ចែង គេមានសិទ្ធិការពារ។ ដល់ពង្ស វាធ្វើខុសពេកចឹងទៅ ខ្ញុំធ្វើមិនបាន មិនប្រជាជនថ្កោលទោសថា ខ្មែរក្រហមអ្នកយកគោ ប្លន់គោក្របីរបស់ប្រជាជន។ ហើយខ្ញុំអត់មានទេ ទៅសួរទៅអ្នកស្រុកភ្នំស្រួចទាំងអស់ ម៉ាចំហៀង ប្អូនឯងបើមិនជឿទៅសួរទៅ។

ដានី ៖ ចុះលោកតា ឈ្មោះ កែវ សាន អត់មានឈ្មោះអីផ្សេង?

សាន ៖ អត់ទេ អត់មាន។

ដានី ៖ ឈ្មោះ កែវ សានចឹងម៉ង?

សាន ៖ បាទ! ទៅសួរណាក៏ចឹងដែរ។

ដានី ៖ អត់មានឈ្មោះ បដិវត្តអីផ្សេងទៀតទេ?

សាន ៖ ហ្នឹងឈ្មោះ បដិវត្ត។

ដានី ៖ ហ្នឹងឈ្មោះ បដិវត្ត ឈ្មោះ កែវ សាន។ ឈ្មោះលោកតាឈ្មោះពីដើម?

សាន ៖ បាទ! នោះឈ្មោះប៉ូចនោះ។

ដានី ៖ បាទ?

សាន ៖ ឈ្មោះ ប៉ូច។ ឈ្មោះ តែមួយនឹង ខ្ញុំអត់មានឈ្មោះច្រើន។

ដានី ៖ ប៉ុន្តែ គេហៅឈ្មោះ ប៉ូច ដែរ?

សាន ៖ អត់ទេ ទៅសួររកអត់ឃើញឥឡូវនឹង មកតាំងពីបួសនៅរៀន ចេញវាបាត់សួរមិនស្គាល់។

ដានី ៖ ឈ្មោះអត់ស្គាល់ បើឈ្មោះ សាន គេស្គាល់?

សាន ៖ ស្គាល់ទាំងអស់ ឲ្យម៉ាចំហៀងខាងត្បូងទន្លេសាប នេះទៅចេះ។

ដានី ៖ ខាងត្បូងទន្លេសាប ខាងណាទៅ ខាងស្រុកអីខ្លះ?

សាន ៖ ខាងត្បូងទន្លេសាបទៅទល់នឹង...។

ដានី ៖ ខាងភ្នំស្រួច ខាងអី?

សាន ៖ បាទ! បសេដ្ឋ។

ដានី ៖ អានឹងគេហៅខាងត្បូងទន្លេសាប?

សាន ៖ បាទ!

ដានី ៖ ខាងកំពង់ឆ្នាំង ខាងខត្តក្ត ខាងអីនឹង?

សាន ៖ បាទ! ខ្ញុំម៉ាចំហៀងខាងត្បូងនឹងខ្ញុំដើរចង់អស់ ទៅនៅត្រង់ណា។

ដានី ៖ ចុះលោកតា ពេលគេសមាហរណកម្មអីនឹង គេអត់មានផ្ដល់តួនាទីឲ្យលោកតា ហើយក៏យ៉ាងម៉េច ខ្ញុំអត់ទាន់ច្បាស់?

សាន ៖ ខ្ញុំនៅៗធ្វើគណបក្ស តំណាងឲ្យគណបក្សក្នុងស្រុក ។

ដានី ៖ ក្នុងស្រុកណា?

សាន ៖ ស្រុកវាលវែងនឹង ។

ដានី ៖ ឥឡូវនឹង?

សាន ៖ ឥឡូវ អត់ទេ អារ៉ែត្រត(Retired) ។

ដានី ៖ ឥឡូវអារ៉ែត្រត ។ ចឹងកាលពីមកដំបូងលោកតាតំណាងយ៉ាងម៉េច?

សាន ៖ តំណាងគណបក្ស ជាសមាជគ្រប់គ្រងការងារគណបក្ស ។

ដានី ៖ គណបក្សអីគេ?

សាន ៖ គណបក្សប្រជាជន ។

ដានី ៖ ចឹងបានន័យថាលោកតាជាប្រធានគណបក្សប្រជាជនស្រុកវាលវែង?

សាន ៖ មិនមែនប្រធានទេ គ្រាន់តែការគ្រប់គ្រងវា ។

ដានី ៖ គ្រប់គ្រងយ៉ាងម៉េចទៅ គេហៅអី?

សាន ៖ ការអប់រំ ។

ដានី ៖ ធ្វើការនៅក្នុងគណបក្សនឹង?

សាន ៖ បាទ!

ដានី ៖ ក្នុងជួរអ្នកដឹកនាំគណបក្សនៅវាលវែង?

សាន ៖ បាទ! គណបក្សទាំងអស់នឹង ។

ដានី ៖ ពីឆ្នាំណាដល់ឆ្នាំណា?

សាន ៖ តាំងពីសមាហរណកម្មហើយ ។

ដានី ៖ សមាហរណកម្មហើយ រហូតដល់ឆ្នាំណា?

សាន ៖ ទើបនឹងឈប់ឆ្នាំទៅមិញ ឈប់២ឆ្នាំ ។

ដានី ៖ ឈប់២ឆ្នាំហើយ ។ ហើយសំនួរចុងក្រោយ ដោយសារលោកតាបានដឹងរឿងរ៉ាវពីតុលាការ ដែលគេបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមអី ចំពោះលោកតាផ្ទាល់លោកតាយល់ឃើញម៉េចដែរ?

សាន ៖ អត់យល់ឃើញម៉េចទេ យល់ឃើញថា ធ្វើតាមពាក្យរបស់សម្ដេចហ៊ុន សែន អានឹងល្អ ។ តែបើពាក្យថាកប់ៗឲ្យជ្រៅទៅ កុំឲ្យកាយវិញ ។ ហ្នឹងហើយ បើសិនយើងកាយដូចហែក

រឿងចឹង ខ្ញុំក៏កូនទាហានប៉ុល ពត ។ អ្នកណាមិនប៉ុលពត ៗទាំងអស់គ្នា ភាគច្រើនបើរកទៅ នៅក្នុងទាហានរបស់សម្តេចហ៊ុន សែន ក៏ប៉ុលពត ។ តែខ្ញុំអត់ប្រាប់ក្មួយឯង ដូចប្រាប់ឈ្មោះមិញចឹង ។ អ្នកណាមិននៅជាមួយខ្ញុំ ទាហាននៅណាក៏នៅជាមួយខ្ញុំ ឃើញទេ ខគួរមានជ័យណាក៏នៅជាមួយ ៗ ។ ហើយចឹងវាដូចគ្នា ប៉ុលពត គាត់ដើរទូទាំងប្រទេសមិនចឹង តែខ្ញុំត្រឹមកងពលមួយមានទាហាននៅសព្វ ឃើញទេ ។ ហើយមានមនុស្សចោទចេតនាជាមួយខ្ញុំអត់ ច្បាស់ជាមាន ។ ដោយសារខ្ញុំធ្វើអី ៗល្អអីចឹងទៅ ។ ហើយចឹងអ្នកប៉ុលពតនឹងខ្លះក៏គាត់ជឿថាប៉ុលពតអាក្រក់ ដល់ខ្លះគេថាប៉ុលពតល្អដែរ ។ ហើយខ្ញុំថា នៅតែប៉ុលពតល្អចឹង ព្រោះគាត់អត់ដែលសម្លាប់ប្រជាជន ហើយគាត់អត់ដែលប៉ះពាល់នៅសិទ្ធិរស់នៅរបស់ខ្ញុំទេ មានតែដឹកនាំឲ្យល្អ ។ ទ្រឹស្តីរបស់គាត់ ជាទ្រឹស្តី តែន័យអនុវត្តទៅក្រោមទៀត មិនមែនគាត់លូកដៃណា អានឹងន័យចឹង ។ ដូចខ្ញុំចឹង ខ្ញុំមានដឹងអី មជ្ឈិមអី ខ្ញុំអត់ដឹងទេ តែន័យក្នុងកន្លែងខ្ញុំក្តាប់ ខ្ញុំក្តាប់ឲ្យល្អ ។ ចឹងពលរដ្ឋគ្រប់គ្រង ពលរដ្ឋស្រឡាញ់ខ្ញុំ ន័យចឹង ។

ដានី : ចុះលោកតាមានប្រសាសន៍មិញ ថាពាក្យរបស់សម្តេចហ៊ុន សែន គាត់មានប្រសាសន៍ថាម៉េច?

សាន : ឈ្នះ ៗទាំងអស់គ្នា អត់មានអ្នកណាចាញ់ អ្នកឈ្នះ ៗទាំងអស់ ប៉ុល ពតក៏ឈ្នះ អ្នកណាក៏ដោយ នៅអ្នកតស៊ូណាទាំងអស់គ្នា សុទ្ធអ្នកឈ្នះ ។ ចង់ឈ្នះពេលឥឡូវ មកធ្វើនយោបាយជាមួយគ្នា អ្នកណាឈ្នះ ៗ ពាក្យគាត់ថាម៉ាមាត់ប៉ុននឹង ឈ្នះ ៗឃើញទេ អត់មានអ្នកណាចាញ់ អត់មានអ្នកឈ្នះ ។ ចឹងពាក្យនឹងអ្នកទាំងអស់គ្នា ត្រូវតែគាំទ្រ បានវាចូលមកសមាហរណកម្ម រំលាយខ្លួនចូលនៅជាមួយរដ្ឋាភិបាល ។ តែបើគាស់កកាយ ពាក្យថាដំបៅវាជាទៅហើយ ទៅហែកហួរទៀត វានាំឲ្យមានជម្ងឺ ។

ដានី : ចឹងលោកតាការបង្កើតតុលាការនឹង គឺជាការហែកដំបៅឲ្យវា?

សាន : ហ្នឹងខ្ញុំយល់ចឹងហើយ ។

ដានី : លោកតាយល់ចឹង?

សាន : បាទ! ព្រោះខ្ញុំយល់ចឹង បានខ្ញុំប្រាប់ថាចឹង ព្រោះនិយាយម្នាង អត់និយាយម្នាងអត់និយាយម្នាង ។

ដានី : បាទ ៗ ខ្ញុំយល់ ។ ប៉ុន្តែមួយទៀត ដោយសារតុលាការនេះ វាកើតឡើងរវាងការព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ដែលគេមានកិច្ចព្រមព្រៀងមួយដើម្បីបង្កើតតុលាការនឹងឡើង?

សាន ៖ បាទ! អានឹងខ្ញុំមិនយល់បានដែរ ព្រោះខ្ញុំអត់មានគំរិះវិជ្ជាអីទេ យល់តែប៉ុននឹង ហើយចង់ថាចិត្ត មិនដឹង ហើយមិនយល់អី មិនឃើញអី ចិត្តនឹងបើសិនណាកុំបន្តរឿងឡើងទៀត វាបានទេ ចឹង ។ វាស្ងាត់ទៅហើយ រឿងអីត្រូវបន្តរឿងទៀត ដូចជាភ្លើងបើរលត់បាត់ទៅហើយ ។ ហើយក្អួយឯងយកអុសទៅគរនៅភ្លើងតិចៗ វាឆេះទៀតហើយ ។

ដានី ៖ បាទ! ខ្ញុំយល់ ។ បានចឹង ខ្ញុំដូចថាជួបលោកតានេះ ដូចជាយូរហើយ ជាង២ម៉ោងជាងហើយ ខ្ញុំគិតថាបញ្ចប់ត្រឹមនឹង ។ ហើយលោកតាមានអីចង់បន្ថែមនូវអ្វី ដែលខ្ញុំអត់បានសួរនាំលោកតា?

សាន ៖ បាទ! ខ្ញុំចង់បន្ថែមថា ព្រោះបញ្ហាណា ដែលពួកអស់នេះ ដាក់ការពិតនេះ ឲ្យពិតទៅអត់អីល្អហើយ សំណូបពររបស់ខ្ញុំចឹង ។ ការពិតគឺពិតៗអីខ្លះ នៅក្នុងសង្គ្រាមៗជំនាន់ណា ជំនាន់ប៉ុលពត មិនមែនវគ្គតែមួយទេ ប៉ុលពតគឺ២វគ្គ ឃើញទេ វគ្គណាមួយ វគ្គវៃលន់ នល់មួយ វគ្គវៃយួន២ ។ ចឹងតែប៉ុលពតមួយ ឃើញទេ ដល់យកប៉ុល ពត មួយ ខ្ញុំអត់ទុកចិត្តឃើញទេ ។ ដួនវៃយួនក៏ដោយសារ ប៉ុល ពត ។ ដល់វៃជំនាន់ លន់ នល់ ក៏ប៉ុល ពតចឹងសម្លាប់ខ្មែរតែប៉ុល ពត មួយទេ ។ នេះដែលខ្ញុំសួរក្អួយឯងខាងដើមចឹង ព្រោះមនុស្ស២នាក់វៃគ្នា ផាប់ទាំងសងខាង ។ ហើយដល់ផាប់ទាំងសងខាង យួនក្អួយឯងអត់សួរផងសួរតែប៉ុលពតមួយ ហើយក្អួយឯងអត់សួរអាមេរិចកាំងផង សួរតែប៉ុលពតមួយ ។ បានខ្ញុំសួរថា រកតែម៉ាចំហៀង អានឹងវាលំបាកតិច មានការលំបាកៗមនុស្សមិនមែនមិនទាន់អស់ទេ ខ្ញុំថាចឹង ។

ដានី ៖ លោកតាអ៊ីដែលខ្ញុំបានសួរនាំលោកតានេះ ខ្ញុំអាចយកទៅសរសេរជាអត្ថបទ ពីរឿងរ៉ាវរបស់លោកតា តាំងពីដើមរហូតមក ។ ហើយយើងអាចចុះផ្សាយតាមទស្សនាវដ្តីស្វែងរកការពិត តាមអីផ្សេងៗ បានដែរអត់លោកតា?

សាន ៖ បាទ! អត់អីទេ ។ ខ្ញុំនិយាយអួតថា រឿងចាប់គេចាប់ឯង ខ្ញុំជិះឡានចូលទៅដែរ ដូចខ្ញុំនិយាយជាមួយប្អូនឯង ចង់ទៅភ្នំពេញជិះទៅ ជំនាន់នោះខ្ញុំប្រហើនៗជាងគេ តែគេ៣០-៤០នាក់ ខ្ញុំចូលតែឯងក៏ចូល ប្រហើនៗចង់ប្រហែល...រឿងចិនចាប់ទៅចាប់អាយាមតាមស្ពានតាអី(សើច) ។

ដានី ៖ ចឹងខ្ញុំអរគុណច្រើនលោកតា ។

សាន ៖ បាទ!

«ចប់»